ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខៈ ០៥៤/២៦ គ.ជ.ប.ជ

# របាយការណ៍
# ស្តីពី
# ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# ប្រចាំខែឧសភា និងទិសដៅខែមិថុនា ឆ្នាំ២០២៦

## I. ស្ថានភាពទូទៅ

ពិភពលោក នៅតែប្រឈមដោះស្រាយវិបត្តិសេដ្ឋកិច្ចជាសកល ផលប៉ះពាល់នៃគ្រោះធម្មជាតិ ដែលកើតឡើងដោយបម្រែបម្រួលអាកាសធាតុ និងជម្លោះប្រដាប់អាវុធដ៏រ៉ាំរ៉ៃ និងសង្គ្រាមបង្ហូរឈាម វិបត្តិនយោបាយបានកើតឡើងជាបន្តបន្ទាប់ និងរាលដាលពីតំបន់មួយទៅតំបន់មួយ ចរន្តគាំពារនិយម ភាពក្រីក្រចេះតែមានចំនួនកើនឡើងជាបន្តបន្ទាប់ ជាបុព្វហេតុជំរុញឱ្យមនុស្សរាប់លាននាក់ បង្ខំចិត្តចាកចេញពីផ្ទះសម្បែង ឬទីតាំងដែលខ្លួនរស់នៅ ហើយធ្វើទេសន្តរប្រវេសន៍ដោយគ្មានការត្រៀមទុក ដែលក្លាយជាចលនាំហូរពលករដែលគ្មានឯកសារ ខ្វះការគ្រប់គ្រង និងប្រឈមយ៉ាងខ្លាំងទៅនឹងកង្វះសុវត្ថិភាព អំពើរំលោភបំពាន ការកេងប្រវ័ញ្ចជាច្រើនរូបភាព និងអំពើជួញដូរមនុស្ស។ អំពើជួញដូរមនុស្ស ការរំលោភសិទ្ធមនុស្ស រំលោភសណ្តាប់ធ្នាប់ពិភពលោក ច្បាប់អន្តរជាតិ ជារឿងស្មុគស្មាញ និងជាបញ្ហាដ៏ធំមួយនៃសង្គមមនុស្សជាតិក្នុងពិភពលោក ដែលកើតឡើងដោយសារកត្តារួមផ្សំជាច្រើន ។

ប្រព័ន្ធផ្សព្វផ្សាយដ៏សម្បូរបែប និងការផ្សព្វផ្សាយ នៃបណ្តាញសារព័ត៌មាននានាមួយចំនួន បានលាយឡំទាំងព័ត៌មានពិត និងមិនពិត រួមទាំងនិន្នាការ និងភូមិសាស្ត្រនយោបាយផងនោះ បានវាយតម្លៃអំពីស្ថានភាពនៃបទល្មើសជួញដូរមនុស្សនៅកម្ពុជា។ ទន្ទឹមនឹងនោះការចោទប្រកាន់ពីបណ្តាប្រទេសមួយចំនួន ដែលមានពលរដ្ឋមកប្រព្រឹត្តបទល្មើស ឬមករងគ្រោះនៅកម្ពុជា ក៏បានធ្វើឱ្យមានការភ័ន្តច្រឡំ និងវាយតម្លៃជាអវិជ្ជមានលើស្ថានភាពសន្តិសុខនៅកម្ពុជា ដែលផ្ទុយពីឆន្ទៈរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងស្ថានភាពពិតជាក់ស្តែងនៅកម្ពុជា ។

ការផ្សព្វផ្សាយអំពីឱកាសការងារ និងការជ្រើសរើសពលករទៅធ្វើការនៅក្រៅប្រទេស ទាំងតាមប្រព័ន្ធផ្លូវការទាំងតាមបណ្តាញសង្គម និងមួយចំនួនធំជាការអូសទាញរបស់បណ្តាញជនល្មើស បានក្លាយជាកត្តាជំរុញ និងទាក់ទាញប្រជាពលរដ្ឋក្នុងតំបន់ និងពីបណ្តាប្រទេសនានា ក្នុងពិភពលោក ក៏ដូចជាប្រជាជនកម្ពុជា ដែលពេញវ័យការងារឱ្យចាប់អារម្មណ៍ និងសម្រេចចិត្តយ៉ាងឆាប់រហ័ស និងផុលផុសក្នុងការធ្វើចំណាកស្រុក ឬធ្វើទេសន្តរប្រវេសន៍ទៅរកការងារ ដែលមានបៀវត្សរ៍ខ្ពស់ ជាពិសេសពាក់ព័ន្ធនឹងសកម្មភាពឆបោក។ បច្ចុប្បន្នអំពើជួញដូរមិនមែនមានតែទម្រង់ប្រពៃណីដូចជា ការបង្ខំឱ្យលក់ខ្លួន ឬការបង្ខំអោយធ្វើការធ្ងន់ធ្ងរនោះទេ ប៉ុន្តែវាបានវិវត្ត ទៅជាការបោកប្រាស់តាមប្រព័ន្ធបច្ចេកវិទ្យា (Cyber-scams) និងការបង្ខាំងមនុស្សឱ្យធ្វើការខុសច្បាប់តាមអនឡាញ។ ការវិវត្តលឿននៃបច្ចេកវិទ្យា និងល្បិចកលខ្ពស់របស់ឧក្រិដ្ឋជន បានប្រើប្រាស់បណ្តាញសង្គម ដើម្បីបោកប្រាស់ជនរងគ្រោះ។

រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ ដែលមានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជាសេនាធិការ បានចាត់ទុកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scam) ជាអាទិភាពមួយក្នុងចំណោមអាទិភាពដទៃទៀត រួមទាំងផលប៉ះពាល់នៃគ្រឿងញៀន គ្រឿងស្រវឹង គ្រោះថ្នាក់ចរាចរណ៍ និងបានដាក់ចេញនូវយុទ្ធសាស្ត្រ និងផែនការសកម្មភាព ដោយខិតខំជំរុញសកម្មភាពឥតឈប់ឈរ ដើម្បីការពារសុវត្ថិភាព និងសន្តិសុខមនុស្ស ក៏ដូចជាសន្តិសុខជាតិទាំងមូល ដើម្បីទ្រទ្រង់ដំណើរការអភិវឌ្ឍន៍គ្រប់ វិស័យ

នៃសង្គមជាតិ។ សម្តេចធិបតី ប្រមុខរាជរដ្ឋាភិបាល បានផ្ញើសារច្បាស់លាស់ និងយ៉ាងម៉ឺងម៉ាត់ដល់អាជ្ញាធរមូលដ្ឋាន ឱ្យបង្ក្រាប Online Scams ឱ្យទាល់តែអស់ជាដាច់ខាត ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់បំផុត ពីព្រោះនេះគឺជាមុខមាត់ប្រទេសជាតិ។

នៅក្នុងខែឧសភានេះ គ្រប់ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព និងរាជធានី ខេត្ត នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅគ្រប់កម្រិត និងដោយមានការចូលរួមគាំទ្រ សហការពីអង្គការដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធ បានធ្វើសកម្មភាពប្រតិបត្តិការយ៉ាងសកម្ម ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដើម្បីឆ្លើយតបនឹងស្ថានភាពប្រែប្រួល ពិបាកប៉ាន់ស្មាននៃបទល្មើសជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតដែលបង្កឡើងដោយឧក្រិដ្ឋជន រួមទាំងបទល្មើសឆបោកតាមប្រព័ន្ធអនឡាញផងដែរ។

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការបង្ការ ទប់ស្កាត់

#### ក.១. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយផ្ទាល់

ក្រុមការងារបង្ការ ទប់ស្កាត់ នៃ គ,ជ,ប,ជ ដឹកនាំដោយក្រសួងអប់រំ យុវជន និងកីឡា ដែលមានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយបានសហការជាមួយអង្គការដៃគូពាក់ព័ន្ធ ធ្វើការផ្សព្វផ្សាយតាមរយៈវេទិកាសាធារណៈ គោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" និងការបញ្ជ្រាបការផ្សព្វផ្សាយតាមកម្មវិធីផ្សេងៗ សរុបចំនួន ២៦,៥៧២លើក មានអ្នកចូលរួមសរុបចំនួន ១,១៩០,៩៩៦នាក់ ក្នុងនោះស្ត្រី ៦៩២,៨១០នាក់ (ធៀបនឹងខែមេសា មានចំនួន ១,៧៦១,៨០៧នាក់) ថយចុះ ៥៧០,៨១១នាក់ ស្មើនឹង ៣២.៣៩% ដូចមានក្នុងតារាងខាងក្រោម៖

*តារាងទិន្នន័យសរុបការផ្សព្វផ្សាយដោយផ្ទាល់*

| ល.រ | សកម្មភាពផ្សព្វផ្សាយ | ចំនួនដង/លើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ច្បាប់ វេទិកាសាធារណៈ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព | ២៦,៤៦៦ | ១,១៧៨,៩៩០ | ៦៨៥,៥៥០ |
| ២ | កម្មវិធីផ្សេងៗ | ១០៦ | ១២,០០៦ | ៧,២៦០ |
| សរុប | | ២៦,៥៧២ | ១,១៩០,៩៩៦ | ៦៩២,៨១០ |
| *(សម្គាល់៖ ចំនួននេះមិនគិតអ្នកដែលបានទទួលព័ត៌មានតាមរយៈការចែកខិត្តប័ណ្ណ បណ្តាញសង្គម ឬការផ្សព្វផ្សាយតាមប្រព័ន្ធអេឡិកត្រូនិកផ្សេងទៀតឡើយ)* | | | | |

❖ **ការផ្សព្វផ្សាយតាមរយៈ ផ្សព្វផ្សាយ វេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព**

គណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ (គ.រ.ប.ជ/គ.ខ.ប.ជ) មន្ទីរ អង្គភាព និងអង្គការដៃគូពាក់ព័ន្ធ បានធ្វើការផ្សព្វផ្សាយផ្ទាល់ដល់ប្រជាពលរដ្ឋរួមគ្នា និងដោយឡែកពីគ្នា តាមរយៈការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ វេទិកាសាធារណៈ និងតាមការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព" សរុបចំនួន ២៦,៤៦៦លើក មានអ្នកចូលរួមសរុបចំនួន ១,១៧៨,៩៩០នាក់ ក្នុងនោះស្ត្រីចំនួន ៦៨៥,៥៥០នាក់ ដូចមានក្នុងតារាងខាងក្រោម៖

| តារាងទិន្នន័យផ្សព្វផ្សាយ វេទិកាសាធារណៈ និងភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | | | | | | |
|---|---|---|---|---|---|---|---|
| ល.រ | ក្រសួង ស្ថាប័ន រាជធានី ខេត្ត | ផ្សព្វផ្សាយ វេទិកាសាធារណៈ | | | ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព | | |
| | | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនលើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| រាជធានី ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | ៣២ | ២,០៥០ | ១,០៧២ | ៧០ | ១៤,០០៨ | ៧,០០៩ |
| ២ | ខេត្តកណ្តាល | ២,៧០៧ | ១៤១,១៤៩ | ៧៦,៩៨៥ | ១,៩០៤ | ៦៤,៤៧៥ | ១២,៧១៤ |
| ៣ | ខេត្តបាត់ដំបង | ៧៥៥ | ២៤,៩៨២ | ១៤,៦៥១ | ៩១៦ | ៤១,៦១៦ | ២៤,៤៥១ |
| ៤ | ខេត្តពោធិ៍សាត់ | ៣៤៩ | ១៣,២០៦ | ៦,៦២២ | ៦១៤ | ៤១,៨៤៧ | ២១,៨៨១ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | ខេត្តសៀមរាប | ១,០៩៤ | ៤៧,៩៩១ | ៣២,៧៣២ | ១,០៩៣ | ៧៨,១៨២ | ៤៣,២៨៤ |
| ៦ | ខេត្តកំពង់ឆ្នាំង | ៣៧៨ | ១៤,២២៩ | ៧,៤៤០ | ៧៣៦ | ២៦,៧៩១ | ១៤,២៤៥ |
| ៧ | ខេត្តកំពង់ចាម | ១,៦៥៧ | ៧០,០៦៥ | ៣៦,០៤១ | ១,៧២៧ | ៩៨,៩២៨ | ៥២,៧៧៧ |
| ៨ | ខេត្តព្រះសីហនុ | ១៤ | ១,០៨៣ | ២៥២ | | | |
| ៩ | ខេត្តព្រះវិហារ | ០៩ | ៨៣១ | ៤០៤ | ០១ | ៧៥ | ៦៤ |
| ១០ | ខេត្តស្វាយរៀង | ៤៥៣ | ១៧,៩៧៤ | ១០,៦៧៩ | ៤៧៤ | ២៤,៧៤៩ | ១៣,៩៦៤ |
| ១១ | ខេត្តប៉ៃលិន | ៣៧ | ៦៦១ | ២៩៥ | | | |
| ១២ | ខេត្តកោះកុង | ៣០ | ១០៦ | ៨៤ | ២,០៨៤ | ៤០,១៦៣ | ១៨,៤៧០ |
| ១៣ | ខេត្តកំពត | ១,១១១ | ៥៥,៤៩៧ | ២៨,០៨៥ | ១,០០៤ | ៥០,១៥៤ | ២៥,០០២ |
| ១៤ | ខេត្តកំពង់ធំ | ២៩៩ | ១១,១៧៩ | ៦,៧៧០ | ៩៦២ | ២០,៦៣៩ | ៨៣,៥៥២ |
| ១៥ | ខេត្តតាកែវ | ១១៥ | ១៩,១៩០ | ២២,៥៦៨ | ៨១ | ៣,១៥៧ | ១,៤៤៩ |
| ១៦ | ខេត្តក្រចេះ | ៧៧ | ២,៥១២ | ១,៦០៦ | | | |
| ១៧ | ខេត្តកែប | ១០៦ | ៤,៨៣០ | ២,៤៨៥ | ៩៦ | ៧,៥៤៩ | ៣,៨០៣ |
| ១៨ | ខេត្តកំពង់ស្ពឺ | ១២១ | ៤,៧៦២ | ២,៤៣១ | ៦២៥ | ២៩,០៣៧ | ១៦,៩១៨ |
| ១៩ | ខេត្តស្ទឹងត្រែង | ១៤៨ | ៥,២០៨ | ២,៩៥០ | ១៨៦ | ១១,៦៥៧ | ៦,៥៧២ |
| ២០ | ខេត្តរតនគិរី | ៣១៧ | ១៥,៤៤៤ | ៧,៦២៣ | ៥៨០ | ២៦,៩២៥ | ១៣,១៩៥ |
| ២១ | ខេត្តព្រៃវែង | ៧២៥ | ២៥,០៦៧ | ១៣,២១៦ | ៩៧៧ | ៤៧,៨៥០ | ២៦,៧៥៩ |
| ២២ | ខេត្តត្បូងឃ្មុំ | ៦៩ | ១,៣៩៥ | ៨១៨ | ១៤៣ | ៤,៣៦៩ | ១,៩៦៨ |
| ២៣ | ខេត្តបន្ទាយមានជ័យ | ១៨ | ១,៣៧៣ | ១,០១៥ | ១,២១៧ | ២០,៧០៤ | ១២,៥២៨ |
| ២៤ | ខេត្តឧត្តរមានជ័យ | ១៥ | ៣៩០ | ២៥៩ | ១៧១ | ៨៤៨០ | ៤,៨៥០ |
| ២៥ | ខេត្តមណ្ឌលគិរី | ១៣៤ | ៤,៩៧១ | ២,៤២៧ | ៣៥ | ១,១៦០ | ៥៨៥ |
| សរុប | | ១១,០៣៣ | ៥២៧,៩៥៦ | ២៨៥,០៨២ | ១៥,៤៣៣ | ៦៥១,០៣៤ | ៤០០,៤៦៨ |
| សរុបរួម | | ២៦,៤៦៦ លើក | | ១,១៧៨,៩៩០ នាក់ | | ៦៨៥,៥៥០ នាក់ | |

❖ **ការបញ្ជ្រាបការយល់ដឹងតាមរយៈកម្មវិធីផ្សេងៗ**

| ល.រ | រាជធានី ខេត្ត | ចំនួនលើក | ចំនួនអ្នកចូលរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | ខេត្តកណ្ដាល | ០៨ | ១,២៦៥ | ៧៤១ |
| ២ | ខេត្តបាត់ដំបង | ០៧ | ១,៣៩២ | ៧៦១ |
| ៣ | ខេត្តប៉ៃលិន | ០១ | ៥៤ | ១២ |
| ៤ | ខេត្តសៀមរាប | ៣៣ | ១,២៦៨ | ៩៦០ |
| ៥ | ខេត្តកំពង់ឆ្នាំង | ១០ | ២០៧ | ១០០ |
| ៦ | ខេត្តកំពង់ចាម | ១២ | ៣,២០២ | ២,៥៧២ |
| ៧ | ខេត្តកំពត | ២០ | ៣,២៤៨ | ១,៧០៥ |
| ៨ | ខេត្តឧត្តរមានជ័យ | ០១ | ២១ | ១២ |
| ៩ | ខេត្តបន្ទាយមានជ័យ | ០៤ | ៦៧១ | ៦៤ |
| ១០ | ខេត្តកំពង់ស្ពឺ | ០៩ | ១៧៨ | ៨៤ |
| ១១ | ខេត្តមណ្ឌលគិរី | ០១ | ៥០០ | ២៤៩ |
| សរុប | | ១០៦ លើក | ១២,០០៦ នាក់ | ៧,២៦០ នាក់ |

## គ.២. ការលើកកម្ពស់ការយល់ដឹងតាមរយៈការអប់រំផ្សព្វផ្សាយដោយមិនផ្ទាល់

❖ **ការផលិត និងចែកផ្សាយ សម្ភារផ្ដល់ព័ត៌មាននិងអប់រំ IEC ( Information Education Communication Materials)**

▪ រាជធានីភ្នំពេញ៖ រដ្ឋបាលក្រុងភ្នំពេញបានផ្សព្វផ្សាយតាមរយៈ DVD Video ផ្ដល់ការអប់រំ ស្ដីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់អ្នកទេសចរសរុបចំនួន ៨២៥,០០០នាក់ ទេសចរជាតិ ៨១០,០០០នាក់ ទេសចរបរទេស ១៥,០០០នាក់ (តាមផ្លូវថ្មើជើងចតុមុខ)។

▪ ខេត្តសៀមរាប

- រដ្ឋបាលក្រុងសៀមរាប និងស្រុកពួក ចែកខិត្តប័ណ្ណផ្សព្វផ្សាយពីគោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ការធ្វើចំណាកស្រុក ការស្វែងរកជំនួយ និងលេខទូរស័ព្ទអាជ្ញាធរមានសមត្ថកិច្ច ជូនប្រជាពលរដ្ឋ បានចំនួន ៩,៣០៣សន្លឹក

- មជ្ឈមណ្ឌលការងារខេត្ត ផ្សព្វផ្សាយនិងចែកខិត្តប័ណ្ណ/កម្មវិធី អំពីព័ត៌មានទីផ្សារការងារ បានចំនួន ១,០០០ខិត្តប័ណ្ណ/កម្មវិធី។

▪ ខេត្តបន្ទាយមានជ័យ

- អង្គការសាម៉ារីតាន់ភីសសង្គ្រោះអន្តរជាតិ បានចែកខិត្តប័ណ្ណអំពីរួមគ្នាទប់ស្កាត់អំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកដោយសុវត្ថិភាព ដល់ពលករ និងសហគមន៍ សរុបចំនួន ២២៩នាក់ ស្រី ៨៤នាក់

- អង្គការតំណក់ទឹក បានចុះចែកលេខទូរស័ព្ទហតឡាញបន្ទាន់ ចំនួន ៣លើក និងចែកខិត្តប័ណ្ណផ្សព្វផ្សាយ ចំនួន ១៧៣សន្លឹក ដល់ពលរដ្ឋក្នុងសហគមន៍ចំនួន ១៧៣នាក់ ស្រី ៦៤នាក់។

▪ ខេត្តឧត្តរមានជ័យ៖ បានចុះអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ សិស្សានុសិស្ស និងចែកខិត្តប័ណ្ណចំនួន ១,០៨០សន្លឹក នៅតាមគោលដៅទេសចរណ៍ចំនួន ៤៣កន្លែង រួមមាន៖ រមណីយដ្ឋានប្រវត្តិសាស្ត្រអន្លង់វែង តំបន់វប្បធម៌ប្រវត្តិសាស្ត្រប្រាសាទបុរាណ តំបន់ធម្មជាតិ កសិ-ទេសចរណ៍ តំបន់គោលដៅទេសចរណ៍ និងសហគមន៍ទេសចរណ៍ អេកូទេសចរណ៍ មានចំនួន ៧កន្លែង។

❖ **ការផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប្រព័ន្ធអេឡិកត្រូនិក**

▪ ខេត្តសៀមរាប៖ មន្ទីរព័ត៌មាន បានផលិតកម្មវិធី២សំខាន់ៗ ធ្វើការផ្សាយផ្ទាល់តាមរយៈវិទ្យុជាតិនគរភ្នំ និងទូរទស្សន៍ជាតិខេត្ត ទូរទស្សន៍ខ្សែកាបអង្គរ តាមប្រព័ន្ធអនឡាញ ស្ដីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ ការធ្វើចំណាកស្រុកខុសច្បាប់ និងការទប់ស្កាត់ការប្រើប្រាស់គ្រឿងញៀនខុសច្បាប់ បានចំនួន ៤១លើក ក្នុងនោះផ្សាយផ្ទាល់ ១២លើក ចាក់ផ្សាយឡើងវិញ ២៩លើក។

▪ ខេត្តកណ្ដាល

- ក្រុមការងារផ្នែកព័ត៌មានលេខាធិការដ្ឋាន គ.ខ.ប.ជ បានធ្វើការផ្សព្វផ្សាយច្បាប់ ស្ដីពីការជួញដូរមនុស្ស ការឆបោកតាមប្រព័ន្ធអនឡាញ និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន តាមប្រព័ន្ធហ្វេសប៊ុក

- ក្រុមការងារក្រុងសំពៅពូន បានផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ តាមស្ថានីយ៍វិទ្យុ ទូរទស្សន៍ តេលេក្រាម ហ្វេសប៊ុក ចំនួន ៥លើក។

▪ ខេត្តកំពង់ចាម៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយស្ដីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព នៅស្ថានីយវិទ្យុ ទូរទស្សន៍ តាមតេលេក្រាម និងហ្វេសប៊ុក ចំនួន ៣លើក និងចាក់ផ្សាយ ១២០ដង ក្នុង១ខែ។

▪ ខេត្តព្រៃវែង៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយសារអប់រំនៃការជួញដូរមនុស្ស តាមវិទ្យុបារាយណ៍អណ្ដែត បានចំនួន ៥០ដង ដោយក្នុង១ថ្ងៃ ៥លើក។

▪ ខេត្តកោះកុង៖ មន្ទីរព័ត៌មាន បានផ្សព្វផ្សាយច្បាប់ ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ តាមវិទ្យុ បានចំនួន ១៨០លើក។

▪ ខេត្តត្បូងឃ្មុំ៖ មន្ទីរព័ត៌មាន បានចាក់ស្ប៉តអប់រំតាមរយៈវិទ្យុជាតិ ស្ដីពីការជួញដូរក្រៅប្រទេស បានចំនួន ១០៨ដង និងខ្លឹមសាររឿងពាក់ព័ន្ធការជួញដូរផ្លូវភេទចំនួន ៣ដង។

▪ **ខេត្តកំពង់ស្ពឺ៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយតាមវិទ្យុជាតិគិរីរម្យ អំពីស្បូតការប្រយុទ្ធប្រឆាំងអំពើជួញដូរស្ត្រី និងកុមារ រៀងរាល់ថ្ងៃក្នុងមួយថ្ងៃផ្សាយ ២០លើក សរុបចំនួន ៦០០លើក។

▪ **ខេត្តតាកែវ៖** មន្ទីរព័ត៌មាន បានផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ តាមវិទ្យុ បានចំនួន ១២០ដង។

▪ **ខេត្តប៉ៃលិន៖** មន្ទីរព័ត៌មាន ផ្សព្វផ្សាយតាមរយៈវិទ្យុ និងទូរទស្សន៍ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ក្នុងមួយថ្ងៃ៨លើក ស្មើនឹង ៤៩៦លើក ក្នុងមួយខែ។

▪ **ខេត្តបន្ទាយមានជ័យ៖** បានផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ជាតិខេត្ត ស្តីពីការទប់ស្កាត់ការជួញដូរមនុស្ស ការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ការទប់ស្កាត់អំពើហិង្សា និងការងារយេនឌ័រ ចំនួន ១៤លើក។

❖ **ការចូលរួមជាវាគ្មិនក្នុងកម្មវិធីផ្សេងៗ និងនៅតាមស្ថានីយវិទ្យុ ទូរទស្សន៍**

▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួមជាគណៈអធិបតី និងជាវាគ្មិន ក្នុងសិក្ខាសាលា ស្តីពីវិធានការ បង្ការទប់ស្កាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់ និងទេសន្តរប្រវេសន៍ ក្រោមអធិបតីភាព ឯកឧត្តម នេត្រ ភក្ត្រា រដ្ឋមន្ត្រីក្រសួងព័ត៌មាន។

▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជបណ្ឌិត ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញផ្តល់បទសម្ភាសន៍ជូន ទូរទស្សន៍បាយ័ន ស្តីពីការយល់ដឹងអំពីសុវត្ថិភាព និងការការពារខ្លួន ពីអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ការឆបោក និងការរំលោភបំពានតាមប្រព័ន្ធអនឡាញ ដើម្បីផ្សព្វផ្សាយជាសារអប់រំ នាឱកាសពិធីអបអរសាទរខួបអនុស្សាវរីយ៍ លើកទី៨១ ថ្ងៃកំណើតនគរបាលជាតិកម្ពុជា ១៦-ឧសភា-២០២៦ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

▪ លោកឧត្តមសេនីយ៍ទោ រ៉ែន សុភ័ក្ត្រវឌ្ឍនា ប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានចូលរួមជាវាគ្មិន ក្នុងកម្មវិធីផ្សព្វផ្សាយ ស្តីពីការយល់ដឹងអំពីហានិភ័យ និងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្សក្នុងសហគមន៍ ដែលរៀបចំដោយគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តស្វាយរៀង នៅក្រុង ស្រុកចំនួន៤ មាន៖ ស្រុកស្វាយជ្រំ ស្រុករមាសហែក ស្រុករំដួល និងក្រុងស្វាយរៀង។

▪ **ខេត្តសៀមរាប៖** សមាជិកលេខាធិការដ្ឋាន គ.ខ.ប.ជ តាមមន្ទីរ អង្គភាព រដ្ឋបាលក្រុង ស្រុកនិងអង្គការដៃគូ បានចូលរួមវាគ្មិន ក្នុងកម្មវិធីសន្ទនាមតិ និងកម្មវិធីយើងធ្វើបាន និងវេទិកាសាធារណៈ បានចំនួន ៤លើក៖

- ស្នងការដ្ឋាននគរបាលខេត្ត ជាវាគ្មិនក្នុងវេទិកាសាធារណៈនៅសហគមន៍ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស និងអំពើកេងប្រវ័ញ្ចគ្រប់ទម្រង់ ចំនួន ១លើក អ្នកចូលរួមចំនួន ៤៥០នាក់ ស្រី ២២៥នាក់

- ស្នងការរងទទួលផែនការងារអន្តោប្រវេសន៍ នៃស្នងការដ្ឋាននគរបាលខេត្ត ជាវាគ្មិនស្តីពី រួមគ្នាប្រយុទ្ធប្រឆាំងបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា "ONLINE SCAMS" ចំនួន ១លើក

- ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សស្រុកវ៉ារិន ជាវាគ្មិនស្តីពី ការអប់រំយុវជនពីផលប៉ះពាល់នៃការរៀបអាពាហ៍ពិពាហ៍នៅវ័យក្មេង ចំនួន ១លើក

- តំណាងមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត ជាវាគ្មិនស្តីពី ការផ្តល់សេវាស្តារលទ្ធភាពពលកម្មកាយសម្បទា ដល់ជនមានពិការភាពក្នុងខេត្តសៀមរាប សម្រាប់អភិវឌ្ឍន៍មុខជំនាញ និងការអភិវឌ្ឍន៍មុខរបរដើម្បីបង្កើនជីវភាពរបស់ជនមានពិការភាព ចំនួន ១លើក។

▪ **ខេត្តបាត់ដំបង៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិវិទ្យុជាតិកម្ពុជាខេត្ត ក្រោមប្រធានបទ "ឱកាសការងារក្នុងស្រុក និងការគាំពារសង្គមសម្រាប់កម្មករនិយោជិកនៅក្នុងខេត្តបាត់ដំបង" នៅស្ថានីយវិទ្យុជាតិកម្ពុជា។

▪ **ខេត្តកំពង់ចាម៖** មន្ទីរកិច្ចការនារីខេត្ត បានចូលរួមជាវាគ្មិនក្នុងកម្មវិធីសន្ទនាមតិ នៅមន្ទីរព័ត៌មានខេត្ត ចំនួន ២លើក ស្តីពីការទប់ស្កាត់ផលប៉ះពាល់អំពើហិង្សាលើស្ត្រី និងក្មេងស្រីមានពិការភាព។ និងស្តីពីការការពារសុវត្ថិភាពស្ត្រី និងកុមារពីអំពើរំលោភបំពានតាមប្រព័ន្ធអនឡាញ។

## គ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

❖ ការផ្សព្វផ្សាយ

▪ ខេត្តតាកែវ៖ បានប្រជុំផ្សព្វផ្សាយយុទ្ធនាការប្រយុទ្ធប្រឆាំង និងការទប់ស្កាត់ការជួញដូរមនុស្សខុសច្បាប់ នៅតាមក្រុមហ៊ុនចំនួន ២លើក/២ក្រុមហ៊ុន រួមមានក្រុមហ៊ុន ជាលេអន តែកឃីជីង (ខេមបូឌា)ឯ.ក ក្រុមហ៊ុន ក្សូឈើរ ឡូម៉ិន(ខេមបូឌា)ឯ.ក មានអ្នកចូលរួម ៣៥នាក់ ស្រី ១១នាក់។

❖ ការធ្វើអធិការកិច្ចការងារ

▪ រាជធានីភ្នំពេញ៖ មន្ទីរកាងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានសហការជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចុះអធិការកិច្ចការងារសាមញ្ញ (អន្តរក្រសួងក្នុងវិស័យកម្មន្តសាល) ចំនួន ៦២ទីតាំង។ និងចុះអធិការកិច្ចការងារពិសេសជាមួយក្រសួងចំនួន ៤ទីតាំង និងចុះតាមដានការដាក់កំហិត ១ទីតាំង។

▪ ខេត្តកណ្តាល៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រសួងការងារ ដើម្បីចុះធ្វើអធិការកិច្ចការងារពិសេសចំនួន ១៧លើក ស្មើនឹង១៧សហគ្រាស គ្រឹះស្ថាន ចុះត្រួតពិនិត្យលើបែបបទ ស្តីពីសហគ្រាស និងលក្ខខណ្ឌការងារតាមរយៈបណ្តឹងរបស់កម្មករនិយោជិត។ ក្នុងនោះមានសហគ្រាស គ្រឹះស្ថាន ១៥ ត្រូវបានក្រុមការងារធ្វើការដាក់កំហិត។

### គ.៣.១. ការបង្ការ ទប់ស្កាត់ការជួញដូរមនុស្ស តាមរយៈរូបភាពរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តច្បាប់) បានសម្ភាសជនបរទេស ដែលមកដាក់ពាក្យសុំចុះបញ្ជីរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ តាមផ្លូវច្បាប់ ចំនួន ១៩០នាក់ ស្រី១៣នាក់ មាន១៥សញ្ជាតិ៖ ចិន ១២៧នាក់ កូរ៉េខាងត្បូង ២៥នាក់ ស្រី៦នាក់ អាម៉េរិក ១៦នាក់ស្រី៣នាក់ អូស្ត្រាលី ៦នាក់ស្រី២នាក់ បារាំង ៤នាក់ កាណាដា ២នាក់ ឥណ្ឌូនេស៊ី ២នាក់ ម៉ាឡេស៊ី ១នាក់ ឡាវ ១នាក់(ស្រី) បង់ក្លាដេស ១នាក់ អ៊ុយក្រែន ១នាក់ អង់គ្លេស ១នាក់ ជប៉ុន ១នាក់ស្រី ប៉ាគីស្ថាន ១នាក់ ស្លូវេនី ១នាក់។ *និងវាយតម្លៃបញ្ជូនទៅក្រុមការងារចម្រុះច្រកចេញ-ចូលតែមួយចំនួន ២៧៩នាក់ ស្រី១៣នាក់។*

### គ.៣.២. ការគ្រប់គ្រងស្ថិតិចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ និងជនបរទេស

❖ ការគ្រប់គ្រងស្ថិតិបច្ចុប្បន្នភាពចំណាកស្រុក ចំណូលស្រុក ពលរដ្ឋខ្មែរ

▪ អគ្គស្នងការដ្ឋាននគរបាលជាតិ៖

• ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកទាំងស្របច្បាប់ មិនស្របច្បាប់ និងដាច់ការទាក់ទង រាជធានី ខេត្ត សរុបចំនួន ២៨,៨២៤នាក់ ស្រី ១២,៨៦០នាក់ អនីតិជន ២៩២នាក់ ស្រី ៩៥នាក់ ក្នុងនោះ ៖

○ ស្របច្បាប់ចំនួន ២៤,១៥៣នាក់ ស្រី ១០,៨៦៥នាក់ អនីតិជន ១៣០នាក់ ស្រី ៣៩នាក់

○ មិនស្របច្បាប់ចំនួន ៤,៤៤៤នាក់ ស្រី ១,៩០០នាក់ អនីតិជន ១៥១នាក់ ស្រី ៥២នាក់

○ ដាច់ការទាក់ទងចំនួន ២២៧នាក់ ស្រី ៩៥នាក់ អនីតិជន ១១នាក់ ស្រី ៤នាក់។

• ទិន្នន័យពលរដ្ឋខ្មែរចំណាកស្រុកត្រឡប់ពីក្រៅប្រទេសទាំងស្របច្បាប់ និងមិនស្របច្បាប់ រាជធានី ខេត្ត សរុបចំនួន ១០,១៦១នាក់ ស្រី ៤,៩២៥នាក់ អនីតិជន ៣៥១នាក់ ស្រី ១២៥នាក់។

▪ លេខាធិការដ្ឋាន គ.ខ.ប.ជ/គ.រ.ប.ជ៖ បានធ្វើស្ថិតិពលរដ្ឋខ្មែរចំណាកស្រុកទៅក្រៅប្រទេស និងបានវិលត្រឡប់មកវិញ ដូចមានក្នុងតារាងខាងក្រោម៖

| ល.រ | រាជធានី ខេត្ត | ចំនួនពលករចំណាកស្រុក ទៅក្រៅប្រទេស | | | | ចំនួនពលករវិលត្រឡប់ ពីក្រៅប្រទេស | | | |
|---|---|---|---|---|---|---|---|---|---|
| | | ចំនួនពលករ | | អនីតិជន | | ចំនួនពលករ | | អនីតិជន | |
| | | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី | សរុប | ស្រី |
| ១ | កណ្តាល | ៦,៣៥៨ | ៣,៤១៧ | ៥៥ | ២៥ | ១,៤០៤ | ៤៧០ | ៥៧ | ២៥ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ២ | បាត់ដំបង | ១០៥ | ៥៦ | | | ៨០៣ | ៣៨៩ | | |
| ៣ | ពោធិ៍សាត់ | ៨ | ២ | | | ១ | ១ | | |
| ៤ | សៀមរាប | ២០,៨៦៦ | ៨,២៧៣ | ១,២១៨ | ៥៩៥ | ២៦៩ | ១២១ | ២៣ | ១២ |
| ៥ | កំពង់ឆ្នាំង | ៣៦ | ២ | | | ៦ | ១ | | |
| ៦ | កំពង់ចាម | ១២,៨១៩ | ៥៧៥៦ | | | | | | |
| ៧ | ព្រះវិហារ | ៧២ | ៣៦ | ៧ | ៤ | | | | |
| ៨ | ស្វាយរៀង | ៤,៩៥៣ | ២៦៥៥ | | | ៤,០៥៩ | ១,៦៥៤ | | |
| ៩ | កោះកុង | ១,៣២៥ | ៥៣៩ | ១០០ | ៣៥ | ៩៩ | ៤៩ | ៥ | ២ |
| ១០ | កំពត | ៨,៩៩៨ | ៣,៤១៣ | ៥៥ | ៣២ | ៣,៨០១ | ២,០៨៣ | ៧១ | ៤៨ |
| ១១ | កែប | ២៤៧ | ១២២ | | | ១៥ | | | |
| ១២ | កំពង់ស្ពឺ | ៩២៦ | ១៦៥ | | | ៧ | ៣ | | |
| ១៣ | ព្រៃវែង | ១,៥៧៩ | ១១០៦ | ២ | ១ | ១,២៦២ | ៩៤៣ | | |
| | សរុបរួម | ៥៨,២៩២ | ២៥,៥៤២ | ១,៤៣៧ | ៦៩២ | ១១,៧២៦ | ៥,៧១៤ | ១៥៦ | ៨៧ |

❖ ការទទួលពលរដ្ឋខ្មែរចំណាកស្រុកដែលអាជ្ញាធរបរទេសបញ្ជូនត្រឡប់

+ <u>ស្ថិតិពលរដ្ឋខ្មែរដែលត្រូវអាជ្ញាធរបរទេសបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែន(កម្ពុជា-ថៃ-វៀតណាម)</u>

▪ **ខេត្តកោះកុង៖** លេខាធិការដ្ឋាន គ.ឧ.ប.ជ បានទទួលពលរដ្ឋខ្មែរដែលអាជ្ញាធរថៃបញ្ជូនត្រឡប់តាមច្រកទ្វារព្រំដែនអន្តរជាតិចាំយាម ចំនួន **៥**លើក មានពលករចំនួន **៤៦**នាក់ ស្រី **១៧**នាក់ អនីតិជន **១**នាក់។

▪ **ខេត្តបាត់ដំបង៖** កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកទាំង៤ សហការជាមួយសមត្ថកិច្ចថៃ បានទទួលប្រជាពលរដ្ឋខ្មែរ គ្មានលិខិតឆ្លងដែនត្រឡប់មកវិញចំនួន **៧**លើក មានពលករចំនួន **២៦៣**នាក់ ស្រី **៨៥**នាក់ អនីតិជន **២៥**នាក់។

▪ **ខេត្តបន្ទាយមានជ័យ៖** ស្នងការដ្ឋាននគរបាលខេត្ត បានទទួលពលរដ្ឋខ្មែរដែលសមត្ថកិច្ចថៃបញ្ជូនមកវិញចំនួន **១**លើក មានពលករចំនួន **៦៧**នាក់ ស្រី**២៩**នាក់ អនីតិជន **១**នាក់។

▪ **ខេត្តស្វាយរៀង៖** ក្រុមការងារជំនាញនៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលពលរដ្ឋខ្មែររស់នៅតាមទីសាធារណៈនៅប្រទេសវៀតណាម និងប្រជាពលរដ្ឋដែលត្រូវចាញ់បោកមេខ្យល់ឆ្លងដែនទៅប្រទេសចិន ត្រូវបានអាជ្ញាធរវៀតណាមចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ ចំនួន **១**លើក មាន**២**គ្រួសារ មនុស្សចំនួន **៣**នាក់(ស្រី)។

❖ ការទទួលពលករនៅតាមមណ្ឌលទទួលពលករ

▪ មជ្ឈមណ្ឌលសំចត និងស្តារនីតិសម្បទាជនរងគ្រោះប៉ោយប៉ែត បានទទួលពលករខ្មែរចំណាកស្រុកដែលត្រូវអាជ្ញាធរថៃបញ្ជូនត្រឡប់មកកម្ពុជាវិញ សរុបចំនួន **២៣១**នាក់(ប្រុស១៤២នាក់ ស្រី៧១នាក់ កុមារា១៣នាក់ កុមារី៥នាក់)។

▪ មណ្ឌលទទួលពលករកំរៀង បានទទួលពលករខ្មែរបញ្ជូនត្រឡប់ពីអាជ្ញាធរថៃ ចំនួន **៥១៤**នាក់ ក្នុងនោះស្ត្រីមាន **១៧០**នាក់ (ស្ត្រីមានកូនតូចមកជាមួយ **៣៦**នាក់ និងស្ត្រីមានផ្ទៃពោះ **០៦**នាក់ អនីតិជន **៣៤**នាក់ (ស្រី **១០**នាក់))។

**ក.៤. កិច្ចការពារកុមារពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ**

❖ ការផ្សព្វផ្សាយ

▪ **ខេត្តសៀមរាប៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះយុទ្ធនាការផ្សព្វផ្សាយទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ នៅក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្ម ដើម្បីលើកកម្ពស់ការ

យល់ដឹងអំពីការទប់ស្កាត់ការប្រើប្រាស់កម្លាំងពលកម្មកុមារ និងការកំណត់វិធានការចាំបាច់ឆ្ពោះទៅបញ្ចប់ការប្រើប្រាស់ពលកម្មកុមារ ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្ម បានចំនួន **៣លើក/៦សិប្បកម្ម** ដែលមានអាជ្ញាធរមូលដ្ឋានថ្នាក់ស្រុក ឃុំ ភូមិ ម្ចាស់សិប្បកម្ម កម្មករ និងអាណាព្យាបាលកុមារ សរុប ២២៩នាក់ ស្រី ១១៩នាក់។

▪ **ខេត្តកំពង់ចាម៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះយុទ្ធនាការផ្សព្វផ្សាយ បង្ការ និងទប់ស្កាត់ពលកម្មកុមារក្នុងសិប្បកម្មឡឥដ្ឋ និងកសិ-ឧស្សាហកម្ម ចំនួន ៤៤ សហគ្រាស ក្នុងនោះក៏មានការចងបដា និងចុះកិច្ចសន្យាជាមួយអាណាព្យាបាល ព្រមទាំងធ្វើលិខិតធានាអះអាងជាមួយនិយោជក ផងដែរ។

▪ **ខេត្តព្រះសីហនុ៖** ផ្នែកការពារសុវត្ថិភាពកុមារ អង្គការម្លប់តាប៉ាង បានពង្រឹងសមត្ថភាពក្រុមកុមារបណ្តាញនៅតាមឆ្នេរសមុទ្រសរុបចំនួន ៤៧នាក់ ស្រី ១៧នាក់ ដែលជាក្រុមបណ្តាញសម្រាប់ផ្តល់ព័ត៌មានសង្ស័យលើការរំលោភបំពាន ការកេងប្រវ័ញ្ច និងការជួញដូរកុមារ។

▪ **ខេត្តមណ្ឌលគិរី៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះយុទ្ធនាការផ្សព្វផ្សាយ ស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅតាមសហគ្រាស គ្រឹះស្ថាន ផលិតកម្ម-សិប្បកម្ម និងកសិ-ឧស្សាហកម្ម បានចំនួន ៥ សហគ្រាស ដែលមានកម្មករនិយោជិតចូលរួមសរុបចំនួន ៣០០នាក់ ស្រី ១១០នាក់។

**ក.៥. ការលើកកម្ពស់ជីវភាព**

❖ **ការផ្តល់ព័ត៌មានការងារ និងបង្កើនកម្មវិធីសិក្សា សម្រាប់អាជីពការងារ និងវិជ្ជាជីវៈ**

▪ **រាជធានីភ្នំពេញ**

- ទទួលបានសំណើរហ៊ីកហ៊ឺនកូនជាងតាមប្រព័ន្ធស្វ័យប្រវត្តកម្ម (LACMS) បានចំនួន ១សំណើរ មានចំនួនកម្មករនិយោជិតស្នើសរុប ២១នាក់ ស្រី ១៧នាក់

- បានផ្តល់ព័ត៌មាន ស្តីពីតម្រូវការកម្លាំងពលកម្មក្នុងរាជធានីភ្នំពេញ ទៅទីភ្នាក់ងារជាតិមុខរបរ និងការងារ(NEA) ដែលមានសហគ្រាស គ្រឹះស្ថាន ចំនួន ៣៨ទីតាំង កំពុងមានតម្រូវការកម្លាំងពលកម្មចំនួន ៣៤០នាក់ ស្រី ១៨០នាក់ តាមរយៈ Group Telegram មន្ទីរការងារ

- វឌ្ឍនភាពនៃចំនួនសិស្សក្នុងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈសរុប១.៥លាននាក់ ក្នុងរាជធានីភ្នំពេញទិន្នន័យពីអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ (TVET) ក្រសួងការងារ។

▪ **ខេត្តសៀមរាប**

- មជ្ឈមណ្ឌលការងារខេត្ត បានប្រមូលព័ត៌មានជ្រើសរើសកម្លាំងពលកម្មពីគ្រប់ប្រភព បានចំនួន ១៨៤កន្លែង។ បានរៀបចំពិព័ត៌មានការងារចល័ត ១លើក ដែលមានប្រជាពលរដ្ឋ យុវជន និងអតីតពលករចូលរួមសរុប ៨០០នាក់ ស្រី ៥០០នាក់។ បានទទួលចុះឈ្មោះអ្នកស្វែងរកការងារធ្វើ ចំនួន ៦១នាក់ ស្រី ២៧នាក់ (ពលករ ១១នាក់ ស្រី ៦នាក់)។ បានផ្ទូរផ្គងនិងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅឱ្យនិយោជក បានចំនួន ១៥១នាក់ ស្រី ១០៣នាក់ (ពលករ ២០នាក់ ស្រី ១២នាក់)។ អ្នកទទួលបានការងារធ្វើ ១២៩នាក់ ស្រី ៩១នាក់ (ពលករ ១៥នាក់ ស្រី១០នាក់)។ ផ្តល់ការប្រឹក្សាអំពីអាជីពការងារ និងវិជ្ជាជីវៈដល់អ្នកស្វែងរកការងារធ្វើ ចំនួន ១៦៦នាក់ ស្រី ១១០នាក់។ បានចែកខិត្តប័ណ្ណអំពីព័ត៌មានទីផ្សារការងារ បានចំនួន ១,០០០ខិតប័ណ្ណ/កម្មវិធី។

- វិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ បានចុះផ្សព្វផ្សាយអំពីនីតិវិធីដាក់សិស្សចុះកម្មសិក្សា និងសម្របសម្រួលឱកាសការងារ ថ្នាក់សញ្ញាបត្របច្ចេកទេសនិងវិជ្ជាជីវៈ១ (កម្មវិធី១.៥លាននាក់) លើជំនាញសេវាបរិក្ខាត្រជាក់ក្នុងគេហដ្ឋាន នៅវិទ្យាស្ថានជាតិពហុបច្ចេកទេសអង្គរ ចំនួន ១លើក។

- មន្ទីរឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកទេស និងនវានុវត្តន៍ខេត្ត បានជំរុញ និងលើកទឹកចិត្តដល់សហគ្រិន ដោយបានណែនាំពីចំណុចដែលត្រូវកែលម្អ និងចំណុចត្រូវធ្វើបន្ថែមទៀត ដើម្បីផលិតកម្មមានដំណើរការ

និងបានជួយកម្មករឱ្យមានការងារធ្វើនៅនឹងកន្លែង នៅក្នុងកម្មវិធីចុះអធិការកិច្ចតាមដាន នៅតាមមូលដ្ឋានអាជីវកម្ម បានចំនួន១៨មូលដ្ឋាន សរុបមនុស្សចំនួន ៦១នាក់ ស្រី ២៨នាក់។

- មន្ទីរពាណិជ្ជកម្មខេត្ត ក្រុមការងារជំរុញទីផ្សារសម្រាប់កសិកម្មខ្នាតតូច បានរៀបចំវេទិកាពហុភាគីអ្នកពាក់ព័ន្ធខ្សែចង្វាក់តម្លៃបន្លែសុវត្ថិភាព ភូមិបុស្សគរ និងភូមិគីឡូតាឈើម ឃុំគោកធ្លកក្រោម ស្រុកជីក្រែង ដោយមានការចូលរួមពីមន្ត្រីបង្គោល CVI,BCF ប្រធាន អនុប្រធាន សមាជិកចង្កោមអាជីវកម្ម អ្នកប្រមូលទិញ និងមេភូមិ សរុបចំនួន ៦៧នាក់ ស្រី៤៣នាក់។

- **ខេត្តកណ្តាល៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានធ្វើការផ្សព្វផ្សាយឱកាសការងារជូនបងប្អូនប្រជាពលរដ្ឋ ជាពិសេសពលករដែលវិលត្រឡប់មកកម្ពុជាវិញចំនួន ២០៧លើក តាមបណ្តាញសង្គម ដែលមានតម្រូវការកម្លាំងពលកម្មចំនួន ១១,៧២៨កន្លែង ក្នុងសហគ្រាស គ្រឹះស្ថានចំនួន៩៦ ។

- **ខេត្តពោធិ៍សាត់៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរកការងារឱ្យពលករវិលត្រឡប់ពីប្រទេសថៃ ចំនួន ៦,៧៤១នាក់ ស្រី ៣,១១៤នាក់ ក្នុងចំណោមពលករចំនួន ១០,១៥២នាក់ ស្រី ៤,៦៤៥នាក់ ក្នុងខែនេះមាន ១,៧៤៤នាក់ ស្រី ៧៩២នាក់។

- **ខេត្តកំពត៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានរកការងារឱ្យពលករវិលត្រឡប់ពីប្រទេសថៃ ចំនួន ៥,៧៨៣នាក់ ស្រី ២,៦៨៣នាក់ ក្នុងចំណោមពលករចំនួន ៦,៣៦៣នាក់ ស្រី ២,៩៤៦នាក់។

- **ខេត្តប៉ៃលិន**

- បានរកការងារឱ្យពលករវិលត្រឡប់ពីប្រទេសថៃ ចំនួន ២០នាក់ ស្រី ៩នាក់ ក្នុងខែនេះមានចំនួន ៤នាក់ ស្រី ១នាក់

- បានផ្សព្វផ្សាយព័ត៌មានទីផ្សារការងារក្នុងខេត្តប៉ៃលិន តាមរយៈការចងបដាព័ត៌មាន នៅតាមទីតាំងឃុំ សង្កាត់ ការចែកខិត្តប័ណ្ណ និងការផ្សព្វផ្សាយតាមផេកហ្វេសប៊ុកផ្លូវការ របស់មន្ទីរការងារ ១លើក។ បច្ចុប្បន្នមានសហគ្រាសចំនួន ១២ កំពុងមានតម្រូវការជ្រើសរើសកម្មករនិយោជិតចំនួន ៥៧នាក់ ស្រី ២៩នាក់។

- **ខេត្តព្រះវិហារ៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានផ្សព្វផ្សាយឱកាសការងារដល់បងប្អូនប្រជាពលរដ្ឋកំពុងស្វែងរកការងារធ្វើ តាមរយៈហ្វេសប៊ុកផេក និងគ្រុបតេលេក្រាមមន្ទីរការងារ ជាមួយសហគ្រាស គ្រឹះស្ថានក្នុងខេត្ត និងចែកខិត្តប័ណ្ណផ្សព្វផ្សាយចំនួន ៣៦សន្លឹក អ្នកទទួលបាន ២៤៦នាក់ ស្រី ១១៣នាក់។

- **ខេត្តមណ្ឌលគិរី៖** មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះស្រង់ស្ថិតិតាមសហគ្រាស គ្រឹះស្ថាន ដែលកំពុងមានតម្រូវការជ្រើសរើសកម្មករនិយោជិតក្នុងខេត្ត សរុបចំនួន ២៧៦នាក់ ស្រី ១១៣នាក់។

❖ ការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបំណិនជីវិត

- **ខេត្តស្វាយរៀង៖** មន្ទីរការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានសហការជាមួយក្រុមហ៊ុនចំនួន៥ បើកវគ្គបណ្តុះបណ្តាលដោយបានបញ្ជ្រាបការយល់ដឹងអំពីចំណាកស្រុកប្រកបដោយសុវត្ថិភាព រួមបញ្ចូលជាមួយនូវប្រធានបទ ស្តីពីបំនិនជីវិត អាហារូបត្ថម្ភ គ្រឿងញៀន និងសុវត្ថិភាពចរាចរណ៍ ការគ្រប់គ្រងសារធាតុគីមី ភាពជាអ្នកដឹកនាំក្រុមល្អ ដើម្បីបង្កើនផលិតភាពផលិតផល ច្បាប់ស្តីពីការងារសុខភាព និងសុវត្ថិភាពការងារ និងការជួយសង្គ្រោះបឋមចំនួន ៩វគ្គ អ្នកចូលរួមចំនួន ១៦៤នាក់ ស្រី១០៧នាក់។

- **ខេត្តកណ្តាល៖** ក្រុងសំពៅពូន បានសហការជាមួយ អង្គការខេមរៈអភិវឌ្ឍន៍សហគមន៍ បើកវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈបំណិនជីវិត ការចិញ្ចឹមសត្វ បណ្តុះផ្សិត ដាំបន្លែ ការកែច្នៃផលិតផលកសិកម្ម ដល់ពលរដ្ឋក្រីក្រក្នុងសហគមន៍ ស្ត្រីមេម៉ាយ ក្មេងបោះបង់ការសិក្សា ដើម្បីលើកកម្ពស់ជីវភាព និងកាត់បន្ថយពីការធ្វើចំណាកស្រុកដោយប្រថុយប្រថាន ១លើក វគ្គមានចូលរួមចំនួន ៦៨នាក់ ស្រី ៣៧នាក់ នៅសង្កាត់ព្រែកស្តី។

▪ ខេត្តកោះកុង៖ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត

- ចុះបើកវគ្គបណ្តុះបណ្តាល ស្តីពីប្រព័ន្ធកសិកម្មចម្រុះ ចំនួន ១វគ្គ នៅឃុំតាតៃក្រោម ស្រុកកោះកុង ខេត្តកោះកុង មានអ្នកចូលរួមចំនួន ៣០នាក់ ស្រី ១៦នាក់

- ចុះផ្សព្វផ្សាយពង្រឹងការអនុវត្តច្បាប់ ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វដល់អាជីវករ បាន ១លើក នៅឃុំស្រែអំបិល ស្រុកស្រែអំបិល ខេត្តកោះកុង មានអ្នកចូលរួមចំនួន ១៩នាក់ ស្រី ១២នាក់

- ចុះបើកវគ្គបណ្តុះបណ្តាលបច្ចេកទេសចិញ្ចឹមមាន់ ជាលក្ខណៈគ្រួសារដល់កសិករ បាន ១វគ្គ នៅឃុំដងពែង ស្រុកស្រែអំបិល មានអ្នកចូលរួមចំនួន ២២នាក់ ស្រី ១៦នាក់

- ចុះបណ្តុះបណ្តាលបច្ចេកទេសជួសជុល និងការថែទាំគ្រឿងយន្តកសិកម្ម បាន ១វគ្គ នៅឃុំជីខលើ ស្រុកស្រែអំបិល ខេត្តកោះកុង មានអ្នកចូលរួមចំនួន ២៥នាក់ ស្រី ២នាក់។

## ខ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

### ខ.១. ការងារអនុវត្តច្បាប់

❖ **ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ**

ក្រុមការងារការអនុវត្តច្បាប់ នៃ គ.ជ.ប.ជ ដឹកនាំដោយអគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី ខេត្ត នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ព្រមទាំងកងរាជអាវុធហត្ថលើផ្ទៃប្រទេស បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបចំនួ ២៤ករណី ៖

ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត ចំនួន ៣០នាក់ ស្រី ៦នាក់ មានជនបរទេស ៤នាក់ (ចិន ២នាក់ បង់ក្លាដេស ១នាក់ ជប៉ុន ១នាក់)។

○ សង្គ្រោះជនរងគ្រោះចំនួន ១៩០នាក់ ស្រី៩០នាក់ ក្នុងនោះមានអាយុក្រោម១៥ឆ្នាំ ១៥នាក់ ស្រី១២នាក់ អាយុ១៥-១៧ឆ្នាំ ២០នាក់ ស្រី១៥នាក់ អាយុ១៨ឆ្នាំឡើង ១៥៥នាក់ ស្រី៦៣នាក់ បានបញ្ជូនទៅមន្ទីរសង្គមកិច្ច ៤៦នាក់ និងទៅគ្រួសារ ១៤៤នាក់។

ក្នុងនោះចែកជា៖

✚ <u>ករណីអំពើជួញដូរមនុស្ស</u>

បង្ក្រាបបាន ១១/០៤ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ១៥១នាក់ ស្រី៥២នាក់ មានអាយុក្រោម១៥ឆ្នាំ ៨នាក់ ស្រី៥នាក់ អាយុ១៥-១៧ឆ្នាំ ៧នាក់ ស្រី២នាក់ អាយុ១៨ឆ្នាំឡើង ១៣៦នាក់ ស្រី៤៥នាក់ បានបញ្ជូនទៅមន្ទីរសង្គមកិច្ច ១៧នាក់ និងគ្រួសារ ១៣៤នាក់។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនសង្ស័យ | ជនរងគ្រោះ(ស្រី) |
|---|---|---|---|
| ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ០១ | ០១ | ០១ |
| ការដឹកជញ្ជូនដោយមានគោលដៅ | ០៤ | ០៤ | ១៧ |
| ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០៦ | ០៦ | ១៣៣(៥២) |
| *សរុប* | *១១ករណី* | *១១នាក់* | *១៥១(៥២)នាក់* |

✚ <u>ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ</u>

បង្ក្រាបបាន ១៣/១០ករណី ឃាត់ខ្លួនជនសង្ស័យចំនួន ១៩នាក់ ស្រី៦នាក់ ជនបរទេស ៤នាក់ (ចិន ២នាក់ បង់ក្លាដេស ១នាក់ ជប៉ុន ១នាក់)។ សង្គ្រោះជនរងគ្រោះចំនួន ៣៩នាក់(ស្រី៣៨នាក់) មានអាយុ

ក្រោម១៥ឆ្នាំ ៧នាក់(ស្រី) អាយុ១៥-១៧ឆ្នាំ ១៣នាក់(ស្រី) អាយុ១៨ឆ្នាំឡើង ១៩នាក់ ស្រី១៨នាក់ បានបញ្ជូនទៅមន្ទីរសង្គមកិច្ច ២៩នាក់ និងគ្រួសារ ១០នាក់។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនសង្ស័យ | ជនបរទេស | ជនរងគ្រោះ(ស្រី) |
|---|---|---|---|---|
| ការចាប់ពង្រត់ ការឃុំឃាំង ឬការបង្ខាំង | ០១ | ០១ | ជប៉ុន១ | ០១ |
| សញ្ញារកម្មទាក់ទងនឹងពេស្យាចារកុមារ | ០៣ | ០៩ | ចិន១ | ២៨(២៨) |
| រូបភាព និងសម្ភារៈអាសអាភាស | ០៤ | ០៤ | បង់ក្លាដេស១ ចិន១ | ០៤(០៤) |
| រូបភាព និងសម្ភារៈអាសអាភាសនៃកុមារ | ០១ | ០១ | | ០១(០១) |
| អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៣ | ០៣ | | ០៣(០៣) |
| អំពើអាសប្រធាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | | ០២(០២) |
| *សរុប* | *១៣ករណី* | *១៩នាក់* | *០៤នាក់* | *៣៩(៣៨)នាក់* |

### គ. កិច្ចការពារជនរងគ្រោះ

#### គ.១. ការទទួល និងសម្ភាសពលករបញ្ជូនទាំងក្នុងប្រទេស និងត្រឡប់ពីក្រៅប្រទេស

▪ ក្រុមការងារការពារជនរងគ្រោះ នៃ គ.ជ.ប.ជ ដឹកនាំដោយ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ មន្ទីរសង្គមកិច្ចរាជធានី ខេត្ត និងអង្គការដៃគូ តាមរយៈនាយកដ្ឋានគាំពារជនរងគ្រោះនៃអគ្គនាយកដ្ឋានសេវាសង្គមកិច្ច បានទទួលជនរងគ្រោះ និងបុគ្គលសង្ស័យថារងគ្រោះដោយអំពើជួញដូរមនុស្សពីប្រទេសម៉ាឡេស៊ី ១នាក់(ស្រី) ជាករណីកេងប្រវ័ញ្ចកម្លាំងពលកម្ម។

➢ *បានធ្វើការកំណត់អត្តសញ្ញាណពីមន្ត្រីនគរបាលយុត្តិធម៌ជំនាញជនរងគ្រោះខាងលើ។*

#### គ.២. ការផ្តល់សេវាគាំទ្រនិងស្តារនីតិសម្បទា

ជនរងគ្រោះ និងងាយរងគ្រោះដោយអំពើជួញដូរមនុស្ស បានបញ្ជូនទៅស្តារនីតិសម្បទា នៅមជ្ឈមណ្ឌលរបស់អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ(IJM) ចំនួន ១នាក់(ស្រី)។

#### គ.៣. ការធ្វើសមាហរណកម្ម

បានសមាហរណកម្មជនរងគ្រោះត្រឡប់ទៅសហគមន៍ ចំនួន ១៨នាក់(ស្រី ១១នាក់ កុមារី ៧នាក់)។

#### គ.៤. ការតាមដានជនរងគ្រោះ

បានតាមដានជនរងគ្រោះចំនួន ៤៨៧នាក់(ប្រុស២០នាក់ ស្រី២៤៨នាក់ កុមារ៨នាក់ កុមារី២១១នាក់)។

#### គ.៥. ការបិទករណីជនរងគ្រោះ

បានបិទករណីជនរងគ្រោះ ចំនួន ២១នាក់(ស្រី១៣នាក់ កុមារី៨នាក់)។

### ឃ.ការងារច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត អនុស្សរណៈនៃការយោគយល់ និងកិច្ចសហប្រតិបត្តិការ

❖ **អនុស្សរណៈនៃការយោគយល់**

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់ ឯកឧត្តម អភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាង ក្រសួងមហាផ្ទៃ និងអង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារ ហៅកាត់ថា CPU «ស្តីពីការរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជននៅព្រះរាជាណាចក្រកម្ពុជា» នៅសាលប្រជុំនៃទីស្តីការក្រសួងមហាផ្ទៃ។

# III. ការលើកកម្ពស់សមត្ថភាព និងការដឹកនាំសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការបណ្តុះបណ្តាល

❖ ការបណ្តុះបណ្តាលក្នុងប្រទេស

| ល.រ | សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | ចំនួនរួម | ចំនួនស្ត្រី |
|---|---|---|---|---|
| ១ | អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយមានកិច្ចសហការគាំទ្រពី រដ្ឋបាលស្រុកថ្មពួក ស្រុកមង្គលបូរី និងអង្គការ UNICEF ក្រោមគម្រោងជំនួយរបស់ សហគមន៍អឺរ៉ុប បានរៀបចំវគ្គបណ្តុះបណ្តាល កិច្ចការពារកុមារក្នុងបរិបទទេសន្តប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តប្រវេសន៍ ធ្វើនៅខេត្តបន្ទាយមានជ័យ។ | ០២ | ១៧៦ | ៦៦ |
| ២ | **ខេត្តសៀមរាប**<br>-រដ្ឋបាលក្រុងសៀមរាប សហការជាមួយអង្គការមូលនិធិអេ២១ រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីការកេងប្រវ័ញ្ចផ្លូវភេទតាមប្រព័ន្ធអនឡាញ ១លើក ដល់សមាជិកក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សក្រុង ចំនួន៣៩នាក់ ស្រី១៨នាក់<br>-អង្គការមូលនិធិអេ២១ សហការជាមួយ អង្គការមូលនិធិហាការ បានផ្តល់វគ្គបណ្តុះបណ្តាលដល់ក្រុមការងារជនបង្គោលរបស់អង្គការហោរការ និងយុវជនអង្គការ PEPY ស្តីពីការកេងប្រវ័ញ្ច និងរំលោភបំពានផ្លូវភេទតាមប្រព័ន្ធអនឡាញ ចំនួន ២លើក អ្នកចូលរួមចំនួន ៨៨នាក់ ស្រី៤៤នាក់។ | ០៣ | ១២៧ | ៦២ |
| ៣ | **ខេត្តបាត់ដំបង៖** សហការជាមួយនាយកដ្ឋានគាំពារជនរងគ្រោះ ក្រសួងសង្គមកិច្ច រៀបចំវគ្គបណ្តុះបណ្តាល ស្តីពីនីតិវិធីកិច្ចការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការរំលោភបំពានគ្រប់ទម្រង់។ | ០១ | ៣៨ | ១៥ |
| | *សរុប* | *០៦ វគ្គ* | *៣៤១ នាក់* | *១៤៣ នាក់* |

### ក.២. សិក្ខាសាលា

❖ **សិក្ខាសាលាក្នុងប្រទេស**

▪ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (ស.អ.យ)

- បានសហការជាមួយគម្រោង JIAC រៀបចំសិក្ខាសាលាពិនិត្យសម្រេចថ្នាក់ជាតិ ស្តីពីគោលការណ៍ណែនាំ «បែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលបានធ្វើបច្ចុប្បន្នភាព» ក្រោមអធិបតីភាព ឯកឧត្តម ញ៉ឹក វណ្ណារ៉ា រដ្ឋលេខាធិការ ក្រសួង ស.អ.យ. នៅសណ្ឋាគារកាំបូឌីយ៉ាណា មានអ្នកចូលរួមសរុប ៧៦នាក់ ស្រី ៤០នាក់។

- បានសហការជាមួយអង្គការ ទេសន្តប្រវេសន៍អន្តរជាតិ (IOM) បានរៀបចំសិក្ខាសាលាវគ្គបណ្តុះបណ្តាលស្តីពី«នីតិវិធីប្រតិបត្តិកិច្ចការងារជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ » ចំនួន ២លើក មានអ្នកចូលរួម ៩២នាក់ ស្រី ៥២នាក់ (ខេត្តបាត់ដំបង ៤៥នាក់ ស្រី២៣នាក់ ខេត្តស្វាយរៀង ៤៧នាក់ ស្រី២៩នាក់)។

▪ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរៀបចំសិក្ខាសាលាក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ចំនួន ៣លើក មានសិក្ខាកាមចូលរួមចំនួន ៧៥នាក់ ស្រី ២១នាក់៖

• សិក្ខាសាលាពិគ្រោះយោបល់ លើសៀវភៅណែនាំស្តីពីការតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ MEL ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨) រយៈពេល៣ថ្ងៃ នៅសណ្ឋាគារ សាន់អែនមូន មានកិច្ចសហការណ៍ពីអង្គការ អេស៊ានអាក់ សិក្ខាកាមចូលរួមចំនួន ៣០នាក់ ស្រី ១០នាក់។

• សិក្ខាសាលាពិគ្រោះយោបល់បន្ត ដើម្បីកសាងសមត្ថភាព ស្តីពីការតាមដាន វាយតម្លៃ និងដកពិសោធន៍ ក្របខណ្ឌ MEL រយៈពេល២ថ្ងៃ សហការរៀបចំដោយ កម្មវិធីអាស៊ាន-អូស្ត្រាលីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (ASEAN-ACT) នៅសណ្ឋាគារ សាន់អែនមូន មានសិក្ខាកាមចូលរួមចំនួន ២២នាក់ ស្រី ០៤នាក់

• សិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ ឆ្លងសមត្ថកិច្ចដែនដីនៃមន្ត្រីអនុវត្តន៍ច្បាប់រវាងខេត្តសៀមរាប កំពង់ចាម កំពង់ធំ និងបន្ទាយមានជ័យ សហការរៀបចំនិងគាំទ្រដោយ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ នៅសណ្ឋាគារសោមាទេវី ក្រុងសៀមរាប ខេត្តសៀមរាប សិក្ខាកាមចូលរួមចំនួន ២៣នាក់ ស្រី ៧នាក់។

❖ **ការចូលរួមសិក្ខាសាលាក្រៅប្រទេស**

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានចាត់បញ្ជូនលោកជំទាវ ឧត្តមសេនីយ៍ទោ វ៉ន **សិរីលក្ខិណា** អគ្គលេខាធិការរង គ.ជ.ប.ជ ចូលរួមសិក្ខាសាលា ស្តីពី «Regional Workshop on the Validation of the Zero Draft ASEAN-Policy Brief on Disability and Trafficking in Persons: Strengthening Protection for Persons with Disabilities» រៀបចំឡើងដោយគណៈកម្មការអន្តររដ្ឋាភិបាលអាស៊ាន ស្តីពីសិទ្ធិមនុស្ស (AICHR) និងមានការគាំទ្រពីកម្មវិធីប្រឆាំងការជួញដូរមនុស្សអាស៊ាន-អូស្ត្រាលី (ASEAN-ACT) នៅទីក្រុងម៉ានីល ប្រទេសហ្វីលីពីន ដោយមានតំណាង AICHR មកពីបណ្តាប្រទេសសមាជិកអាស៊ានទាំង ១១ ប្រទេស។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. កិច្ចប្រជុំ

❖ **ការរៀបចំកិច្ចប្រជុំនៅក្នុងប្រទេស**

▪ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានរៀបចំកិច្ចចំនួន ៥លើក អ្នកចូលរួមចំនួន ៧៧នាក់ ស្រី ២៤នាក់៖

- ពិនិត្យវឌ្ឍនភាពការងារត្រីមាសទី១ និងលើកទិសដៅការងារត្រីមាសទី២ ឆ្នាំ២០២៦ ជំរុញផ្សព្វផ្សាយបទបញ្ជាផ្ទៃក្នុង និងប្រកាសស្តីពីបទវិន័យនគរបាលជាតិកម្ពុជា ចំនួន ២លើក អ្នកចូលរួមចំនួន ៤៥នាក់ ស្រី ១០នាក់

- ត្រៀមឯកសារសវនកម្ម កាលវិយបរិច្ឆេទ ឆ្នាំ២០២៥ ខាងមុខរបស់ការិយាល័យ ផែនការហិរញ្ញកិច្ច និងភស្តុភារ និងការិយាល័យរដ្ឋបាល សរុប ចំនួន ១លើក អ្នកចូលរួមចំនួន ១០នាក់ ស្រី ២នាក់

- កម្រិតបច្ចេកទេស ដើម្បីត្រួតពិនិត្យ និងពិភាក្សាលើអនុស្សរណៈនៃការយោគយល់រវាង ក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាល នៃសាធារណរដ្ឋប្រជាមានិតបង់ក្លាដែស ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន ១លើក អ្នកចូលរួមចំនួន ១៣នាក់ ស្រី ៣នាក់

- ពិនិត្យឯកសារគោលសម្រាប់បណ្តុះបណ្តាល MEL ចំនួន ១លើក អ្នកចូលរួមចំនួន ៩នាក់ ស្រី ៣នាក់។

▪ **ខេត្តសៀមរាប៖** លេខាធិការដ្ឋាន គ.ខ.ប.ជ និងក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ឃុំ សង្កាត់ បានរៀបចំកិច្ចប្រជុំប្រចាំខែ និងកិច្ចប្រជុំពាក់ព័ន្ធ ដើម្បីតាមដាន ពិនិត្យ ពិភាក្សារកដំណោះស្រាយលើភាពប្រឈមនានា ចំនួន ១៤លើក អ្នកចូលរួម ៥៧នាក់ ស្រី ២៨នាក់។

▪ **ខេត្តកណ្តាល៖** លេខាធិការដ្ឋាន គ.ខ.ប.ជ និងក្រុមការងារក្រុង ស្រុក បានរៀបចំកិច្ចប្រជុំប្រចាំខែ និងលើកទិសដៅបន្ត របស់គណៈកម្មធិការខេត្ត តាមប្រព័ន្ធ Zoom ១លើក អ្នកចូលរួមចំនួន ៧៣នាក់ ស្រី ៦៣នាក់។

▪ **ខេត្តកំពង់ចាម៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំខែឧសភា ឆ្នាំ២០២៦ ចំនួន ១លើក សមាសភាពចូលរួម ១០នាក់ ស្រី ៦នាក់។

▪ **ខេត្តព្រះវិហារ៖** លេខាធិការដ្ឋាន គ.ខ.ប.ជ បានរៀបចំកិច្ចប្រជុំបូកសរុបលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ប្រចាំខែមេសា ១លើក អ្នកចូលរួមចំនួន ១០នាក់ ស្រី ៦នាក់។

▪ **ខេត្តត្បូងឃ្មុំ៖** លោកជំទាវ **នី ចាន់ធីតា** អភិបាលរង នៃគណៈអភិបាលខេត្ត និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ខ.ប.ជ បានដឹកនាំក្រុមជំនាញទាំង ០៦ និងលេខាធិការដ្ឋាន ទទួលជួបប្រជុំ និងពិភាក្សាការងារជាមួយក្រុម

ការងារ JICA ដឹកនាំដោយ លោកស្រី MAKIKO KUBOTA ទីប្រឹក្សាជាន់ខ្ពស់ផ្នែកយេនឌ័រ និងការអភិវឌ្ឍ និងក្រុមការងារក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដឹកនាំដោយ លោក យូ សុភ័ក្រ ប្រធាននាយកដ្ឋានគាំពារជនរងគ្រោះ មានអ្នកចូលរួមចំនួន ២៣នាក់ ស្រី ១១នាក់ កិច្ចពិភាក្សាផ្តោតសំខាន់លើការងាររបស់ គ.ខ.ប.ជ ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការផ្តល់សេវាជួយជនរងគ្រោះ នៅសាលាខេត្តត្បូងឃ្មុំ។

**ខ.៣. ជំនួបពិភាក្សាការងារ**

▪ **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ

- បានអនុញ្ញាតឱ្យក្រុមការងារអង្គការ បេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) ដឹកនាំដោយ លោក ជុំ សាឯម ប្រធានអង្គការ IJM ចូលជួបសំណេះសំណាង និងពិភាក្សាការងារ នៅបន្ទប់ការងារ ទីស្តីការក្រសួងមហាផ្ទៃ

- បានទទួលជួបពិភាក្សាការងារ ជាមួយក្រុមការងារ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន JICA នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

▪ **ខេត្តបន្ទាយមានជ័យ**

- ឯកឧត្តម អ៊ុំ រាត្រី អភិបាល នៃគណៈអភិបាលខេត្ត និងជាប្រធានគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានទទួលបដិសណ្ឋារកិច្ចលោកស្រី Matidida Bogner តំណាងប្រចាំប្រទេស នៃអង្គការសហប្រជាជាតិសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ដើម្បីជួបសម្តែងការគួរសម និងពិភាក្សាការងារ។

- លោកស្រី រស់ សុផានី អភិបាលរង នៃគណៈអភិបាលខេត្ត និងជាប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានជួបសម្តែងការគួរសម និងសំណេះសំណាលពិភាក្សាការងារ ជាមួយក្រុមការងារអង្គការបេសកកម្មយុត្តិធម៌អន្តជាតិប្រចាំកម្ពុជា និងតំណាងក្រុមជនធ្លាប់រងគ្រោះ។

## គ. ការងារសម្របសម្រួល

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងលេខាធិការដ្ឋានប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សខេត្ត បានរៀបចំដឹកនាំសម្របសម្រួល និងចូលរួមកិច្ចប្រជុំនានា ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស សរុបចំនួន ៤៤លើក ក្នុងនោះមាន គ.ជ.ប.ជ ៣៦លើក និង គ.រ.ប.ជ/គ.ខ.ប.ជ ០៨លើក។ (ឧបសម្ព័ន្ធ)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងរបស់ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាល ក្នុងការកំណត់យកការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សជាអាទិភាពមួយក្នុងចំណោមអាទិភាពនៃផែនការដែលត្រូវយកចិត្តទុកដាក់ គឺជាថាមពលជំរុញចិត្តឱ្យគ្រប់សមាសភាពក្នុងសង្គមទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ និងដៃគូ ជាតិ និងអន្តរជាតិ ឱ្យរឹតតែប្រឹងប្រែងទ្វេឡើងទៀត
- ច្បាប់ គោលនយោបាយ វិធានការ អនុសាសន៍របស់ប្រមុខដឹកនាំទាំងក្នុងនីតិកាលចាស់ និងថ្មី នៅតែមានគុណតម្លៃសម្រាប់ការអនុវត្ត ជាមូលដ្ឋានបង្អែក និងជាប្រទីបបំភ្លឺផ្លូវសម្រាប់ការកំណត់ការងារជាយុទ្ធសាស្ត្រប្រឆាំងអំពើជួញដូរមនុស្ស
- សន្ធិសញ្ញា កតិកាសញ្ញា អនុសញ្ញា អនុស្សរណៈនៃការយោគយល់ កិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងលិខិតបទដ្ឋានគតិយុត្តជាច្រើនផ្សេងទៀត នៅតែមានតម្លៃជាកិច្ចសហប្រតិបត្តិការទូលំទូលាយលើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ និងអំពើពាក់ព័ន្ធដទៃទៀត
- រចនាសម្ព័ន្ធនៃយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាកម្លាំងស្នូលក្នុងការអនុវត្តការងារ តាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន បានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើពាក់ព័ន្ធទាំងឡាយក្នុងសង្គមកម្ពុជា

- ការចូលរួមឧបត្ថម្ភគាំទ្រពីអង្គការសង្គមស៊ីវិលជាតិ អន្តរជាតិ វិស័យឯកជន និងកិច្ចសហការក្នុងការបំពេញភារកិច្ចតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព គឺជាកម្លាំងសរុប ធនធានសរុប និងមធ្យោបាយសរុប សម្រាប់រួមគ្នាធ្វើសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សដ៏មានសក្តានុពល។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម មួយចំនួនដូចជា៖

- ទាមទារការយកចិត្តទុកដាក់បន្ថែមទៀត លើការចាត់តាំងមន្ត្រីទទួលបន្ទុកឱ្យបានជាក់លាក់ លើការងាររបាយការណ៍ ការងារផែនការ ការងារសម្របសម្រួល ការងាររដ្ឋបាលហិរញ្ញវត្ថុ សម្រាប់អនុវត្តយុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅតាមក្រសួងស្ថាប័ន មន្ទីរអង្គភាពនីមួយៗ ចៀសវាងការផ្លាស់ប្តូរញឹកញាប់ ឬគ្មានអ្នកទទួលខុសត្រូវច្បាស់លាស់
- ត្រូវការពិភាក្សាបន្ថែម លើការកំណត់ឯកតាសម្រាប់ទិន្នន័យនៃរបាយការណ៍ ឧទាហរណ៍ ពាក្យថាជនរងគ្រោះ ជនងាយរងគ្រោះ ជនសង្ស័យថារងគ្រោះ...ដែលធ្វើឱ្យការបូកសរុបទាំងបរិមាណ និងគុណភាព មិនទាន់ស៊ីចង្វាក់គ្នា
- ត្រូវការរៀបចំកែលម្អ រចនាសម្ព័ន្ធ តួនាទី ភារកិច្ច របស់គណៈកម្មាធិការជាតិ គ្រប់លំដាប់ថ្នាក់ ដោយយកចិត្តទុកដាក់បន្ថែមលើការជួញដូរ ដែលពាក់ព័ន្ធនឹងអំពើឆបោកតាមអនឡាញ ដែលមានភាព ស្មុគស្មាញ ដើម្បីឱ្យការធ្វើសកម្មភាព និងទិន្នន័យមានសង្គតិភាព និងកាន់តែជាក់លាក់
- ជនល្មើសមានកលល្បិចខ្ពស់ ក្នុងការធ្វើសកម្មភាពខុសច្បាប់ ជាប្រព័ន្ធ និងអូសទាញមនុស្សឱ្យរងគ្រោះជាបន្តបន្ទាប់ ជាពិសេស នៅក្នុងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា
- ខ្វះការផ្សព្វផ្សាយអំពីលទ្ធផលការងារ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលឆ្លើយតបទៅនឹងការចោទប្រកាន់ ជាពិសេស ករណីជនបរទេស
- ខ្វះវិធីសាស្ត្រសមស្រប និងសង្គតិភាពនៃសារអប់រំ ផ្សព្វផ្សាយ និងគម្រោងសកម្មភាពនានា ដែលអាចធ្វើឱ្យការបង្ការទប់ស្កាត់ អំពើជួញដូរ គ្រប់ទម្រង់ ទទួលបានប្រសិទ្ធភាព ដែលអាចឱ្យមនុស្សផ្លាស់ប្តូរឥរិយាបទមិនធ្វើទេសន្តរប្រវេសន៍ ដោយប្រថុយប្រថាន និងគ្រោះថ្នាក់។

## គ. សេចក្តីសន្និដ្ឋាន និងសំណូមពរ

បទល្មើសជួញដូរមនុស្ស និងបទល្មើសឆបោកតាមអនឡាញ មានភាពប្រទាក់ក្រឡាគ្នា កាន់តែស្មុគស្មាញ និងរីកសាយឆាប់រហ័ស អាស្រ័យដោយការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាទំនើបជាមធ្យោបាយសម្រាប់បង្កើនប្រសិទ្ធភាពបទល្មើសឱ្យកាន់តែមានកម្រិតខ្ពស់ និងអាចខ្ពស់ជាងបច្ចេកទេសដែលសមត្ថកិច្ចប្រើប្រាស់បច្ចុប្បន្ន។ ជនល្មើស និងជនរងគ្រោះ អាចជាមនុស្សតែមួយ ដែលធ្វើឱ្យការកំណត់អត្តសញ្ញាណ មានការលំបាក និងប្រើពេលយូរ។

យុទ្ធសាស្ត្របង្ការទប់ស្កាត់ នៅតែជាអាទិភាព ដែលត្រូវយកចិត្តទុកដាក់ខ្ពស់ និងចាំបាច់ត្រូវមានការចូលរួមពីបណ្តាក្រសួង ស្ថាប័ន អង្គភាព ពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបញ្ចៀសភាពរងគ្រោះ និងកាត់បន្ថយ សក្តានុពលនៃបទល្មើស។ ការបង្កើនការបង្ការទប់ស្កាត់ នឹងអាចការពារ មនុស្សគ្រប់វ័យ តាំងពីដំណាក់កាលដំបូង។

ជាសំណូមពរ ចំពោះ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្នុងយន្តការនៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស៖

- គប្បីចាត់តាំងមន្ត្រីឱ្យទទួលខុសត្រូវ បំពេញតាមរចនាសម្ព័ន្ធគណៈកម្មាធិការគ្រប់ថ្នាក់ឱ្យបានច្បាស់លាស់ ដើម្បីទទួលបន្ទុកការងារទំនាក់ទំនង សម្របសម្រួល ការងាររបាយការណ៍ ការងារផែនការ និងការងាររដ្ឋបាលហិរញ្ញវត្ថុ និងទទួលបានការបណ្តុះបណ្តាលអំពីតួនាទី ភារកិច្ចដែល ឆ្លើយតបទៅនឹងការងារប្រឆាំងអំពើជួញដូរមនុស្ស
- ពង្រឹងរបបប្រជុំ ឱ្យបានទៀងទាត់ ដើម្បីបូកសរុប និងតាមដានការងារលទ្ធផលការងារ ដែលអនុវត្ត ផ្អែកលើផែនការ និងយុទ្ធសាស្ត្រដែលបានកំណត់ ពង្រឹងប្រសិទ្ធភាពឬកែលម្អចំណុចខ្វះខាត ក្នុងក្រុមការងារ

អន្តរក្រសួង ស្ថាប័ន នៅថ្នាក់ជាតិ និងលេខាធិការដ្ឋានខេត្ត ក្រុង ស្រុក ខណ្ឌ (គ.ខ/ស.ប.ជ) ធ្វើរបាយការណ៍ប្រចាំខែ ត្រីមាស និងផ្ញើមកអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ឱ្យបានទាន់ពេលវេលា។

## V. ទិសដៅខែមិថុនា ឆ្នាំ ២០២៦

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈ ការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្តែកលើយុទ្ធសាស្ត្ររួមដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួមគឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់ទម្រង់

២. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី ខេត្ត

៣. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ

៤. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះ នៅតាមបណ្តាក្រសួងស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជាក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត

៥. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេស ការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ

៦. ធ្វើវិសោធនកម្មច្បាប់ស្តីពី ការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដើម្បីឆ្លើយតបទៅនឹងការវិវត្តន៍ថ្មីៗនៃអំពើជួញដូរមនុស្សគ្រប់ទម្រង់

៧. បន្តដោះស្រាយឱកាសការងារ មុខរបរ និងការបង្កើតកម្មវិធីបង្កើនប្រាក់ចំណូល តាមវិធីសាស្ត្រជំនាញ និងគោលនយោបាយ នៃវិស័យពាក់ព័ន្ធ ដល់ប្រជាពលរដ្ឋ ជាពិសេស ក្នុងចំណោមជនទេសន្តរប្រវេសន៍វិលត្រឡប់ និងគ្រួសារជនក្រៀសក្រ

៨. រៀបចកិច្ចប្រជុំវាយតម្លៃពាក់កណ្តាលអាណត្តិ នៃការអនុវត្តផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៤-២០២៨

៩. រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាលស្តីពី ទេសន្តរប្រវេសន៍ ជាមួយអ្នកសារព័ត៌មាន និងអ្នកផលិតមាតិកាផ្សេងៗ ក៏ដូចជាមន្ត្រីព័ត៌មាន ដើម្បីជំរុញការផ្សព្វផ្សាយបន្តឱ្យមានប្រសិទ្ធភាព៕

ថ្ងៃ......... ខែ......... ឆ្នាំមមី អដ្ឋស័ក ព.ស ២៥៧០

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០២៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យ សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យ ឯកឧត្តមអភិសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គជបជ

"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"

-ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន

-សមាជិកក្រុមការងារ គជបជ

-អគ្គលេខាធិការដ្ឋាន គជបជ

"ដើម្បីជូនជ្រាប"

-ឯកសារ កាលប្បវត្តិ

## ឧបសម្ព័ន្ធ

## ការងារសម្របសម្រួល

- លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កិច្ចប្រជុំប្រចាំខែ ដើម្បីតាមដានវឌ្ឍនភាពការងារ បង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា (Online Scams) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅសាលប្រជុំសម្តេចក្រឡាហោម ទីស្តីការក្រសួងមហាផ្ទៃ
  - ដឹកនាំមន្ត្រីជាន់ខ្ពស់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមសិក្ខាសាលាពិនិត្យសម្រេចថ្នាក់ជាតិ ស្តីពីគោលការណ៍ណែនាំស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលបានធ្វើបច្ចុប្បន្នភាព រៀបចំដោយ ក្រសួងសង្គមកិច្ច នៅសណ្ឋាគារ កាំបូឌីយ៉ាណា រាជធានីភ្នំពេញ
  - ជាអធិបតី ក្នុងពិធីបើកសិក្ខាសាលាពិគ្រោះយោបល់ លើសៀវភៅណែនាំ ស្តីពីការតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ MEL ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨)
  - ជាអធិបតី ក្នុងពិធីចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់ រវាងក្រសួងមហាផ្ទៃ និងអង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារ(CPU) ស្តីពីការរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជននៅព្រះរាជាណាចក្រកម្ពុជា នៅសាលប្រជុំទីស្តីការក្រសួងមហាផ្ទៃ
  - ដឹកនាំប្រតិភូ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ចូលរួមកិច្ចប្រជុំពិភាក្សាការងារ ជាមួយ គណៈកម្មការសិទ្ធិមនុស្ស ទទួលបណ្តឹងនិងអង្កេត និងអធិការកិច្ច នៃព្រឹទ្ធសភា (គណៈកម្មការទី១) ដែលដឹកនាំដោយ ឯកឧត្តម ងី ច័ន្ទ្រផល ប្រធានគណៈកម្មការទី១ នៃព្រឹទ្ធសភា នៅសាលប្រជុំកក្កីវិក្រម៣ វិមានព្រឹទ្ធសភា
  - ធ្វើការណែនាំ ស្តីពីការតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ (MEL) ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨) នៅសណ្ឋាគារ សាន់អៃនមូន
  - ជាអធិបតី ក្នុងពិធីបើក និងបិទ វគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ និងមេរៀនសង្គ្រោះបឋមផ្លូវចិត្ត ដល់មន្ត្រីឃុំ និងមន្ត្រីនគរបាលប៉ុស្តិ៍ រដ្ឋបាលឃុំ ក្នុងស្រុកថ្មពួក និងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ
  - ជាអធិបតី ក្នុងសិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការឆ្លងសមត្ថកិច្ចដែនដី នៃមន្ត្រីអនុវត្តន៍ច្បាប់ រវាងខេត្តសៀមរាប កំពង់ចាម កំពង់ធំ និងខេត្តបន្ទាយមានជ័យ ដែលរៀបចំដោយ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សហការនិងគាំទ្រដោយ អង្គការបេសកកម្មយុត្តិធម៌អន្តរជាតិ (IJM) នៅសណ្ឋាគារសោមាទេវី ក្រុងសៀមរាប ខេត្តសៀមរាប
  - ជាអធិបតី ក្នុងពិធីបិទវគ្គបណ្តុះបណ្តាល ស្តីពីការយល់ដឹងអំពីបញ្ហាសុខភាពផ្លូវចិត្ត និងការប៉ះទង្គិចផ្លូវចិត្ត ការកំណត់អត្តសញ្ញាណ ជំនាញគ្រប់គ្រងបឋម ការបញ្ជូនបន្ត និងសហការណ៍ នៅសណ្ឋាគារ អានីក ផាឡេស។
- លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញចូលរួម៖
  - កិច្ចប្រជុំ គណៈកម្មការរៀបចំកិច្ចប្រជុំ ពិនិត្យ វាយតម្លៃ លទ្ធផលអនុវត្តកំណត់ហេតុ កិច្ចសហប្រតិបត្តិការឆ្នាំ២០២៥ និងចុះហត្ថលេខាលើកំណត់ហេតុ ស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំ២០២៦ រវាងក្រសួងមហាផ្ទៃកម្ពុជា និងក្រសួងសន្តិសុខសាធារណៈឡាវ ក្រោមអធិបតីភាព ឯកឧត្តម សន្តិបណ្ឌិត ម៉ៅ ច័ន្ទតារា រដ្ឋលេខាធិការប្រចាំការ នៅទីស្តីការក្រសួងមហាផ្ទៃ
  - កិច្ចប្រជុំ ពិគ្រោះយោបល់បច្ចេកទេសកម្រិតខ្ពស់ ស្តីពីភាពជាដៃគូគម្រោងទេសន្តរប្រវេសន៍ការងារប្រកបដោយយុត្តិធម៌និងប្រសិទ្ធភាព ក្នុងតំបន់អាស៊ាន ក្រោមអធិបតីភាព លោកជំទាវ សុវណ្ណ វណ្ណារតន៍ រដ្ឋលេខាធិការប្រចាំការ ក្រសួងការងារ នៅសណ្ឋាគារ ហៃរហៀល បាយម៉ារៀត រាជធានីភ្នំពេញ
  - ពិធីបើកសិក្ខាសាលាពិគ្រោះយោបល់ លើសៀវភៅណែនាំស្តីពីការតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ (MEL) ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨) ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសណ្ឋាគារ សាន់អេនមូន

- ពិធីចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់ រវាងក្រសួងមហាផ្ទៃ និងអង្គភាពការពារកុមារនៃអង្គការមូលនិធិកុមារ (CPU) «ស្តីពីការរួមចំណែកនៅក្នុងសកម្មភាពមនុស្សធម៌ និងយុត្តិធម៌ព្រហ្មទណ្ឌសម្រាប់អនីតិជននៅព្រះរាជាណាចក្រកម្ពុជា» នៅសាលប្រជុំនៃទីស្តីការក្រសួងមហាផ្ទៃ
- កម្មវិធីបិទសិក្ខាសាលាពិគ្រោះយោបល់ លើសៀវភៅណែនាំស្តីពីការតាមដាន វាយតម្លៃ និងសិក្សាដកពិសោធន៍ (MEL) ផែនការយុទ្ធសាស្ត្រជាតិ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (២០២៤-២០២៨) បានប្រព្រឹត្តទៅរយៈពេល ៣ថ្ងៃ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសណ្ឋាគារ សាន់អេនមូន រីវើសាយ
- ជាអធិបតី ក្នុងពិធីបើក និងបិទ វគ្គបណ្តុះបណ្តាល កិច្ចការពារកុមារ ក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំស្តីពី ការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ និងមេរៀនសង្គ្រោះបឋមផ្លូវចិត្ត ដល់មន្ត្រី គ.ខ.ប.ជ នៅសាលប្រជុំសាលាស្រុកថ្មពួក និងស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ
- កិច្ចប្រជុំ បណ្តុះបណ្តាលកិច្ចការពារកុមារ ក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ និងមេរៀនសង្គ្រោះបឋមផ្លូវចិត្ត ដល់ មន្ត្រី គ.ខ.ប.ជ ក្រោមអធិបតីភាព អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំសាលាស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ
- ជាគណៈអធិបតី ក្នុងពិធីបើកសិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ ឆ្លងសមត្ថកិច្ចដែនដី នៃមន្ត្រីអនុវត្តន៍ច្បាប់ រវាងខេត្ត សៀមរាប កំពង់ចាម កំពង់ធំ និងខេត្តបន្ទាយមានជ័យ នៅសណ្ឋាគារសោមាទេវី ក្រុងសៀមរាប
- ជាអធិបតី ក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការយល់ដឹងអំពីបញ្ហា សុខភាពផ្លូវចិត្ត និងការប៉ះទង្គិចផ្លូវចិត្ត ការកំណត់អត្តសញ្ញាណជំនាញគ្រប់គ្រងបឋម ការបញ្ជូនបន្ត និងការសហការ នៅសណ្ឋាគារ អេនីកផាលេស រាជធានីភ្នំពេញ
- មានមតិស្វាគមន៍ ពិធីបើកសិក្ខាសាលាពិគ្រោះយោបល់បន្ត ដើម្បីកសាងសមត្ថភាព ស្តីពីការតាមដាន វាយតម្លៃ និងដកពិសោធន៍ ក្របខណ្ឌ MEL នៅសណ្ឋាគារ សាន់អែនមូន រាជធានីភ្នំពេញ
- សិក្ខាសាលា ស្តីពីបទដ្ឋានអន្តរជាតិ និងបច្ចុប្បន្នភាពនៃការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្ម សម្រាប់អាជ្ញាធរអនុវត្តន៍ច្បាប់ ក្រោមអធិបតីភាព ឯកឧត្តម **ហេង បូមករា** ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅវិទ្យាស្ថានបច្ចេកទេសធនាគារ
- សិក្ខាសាលាពិគ្រោះយោបល់បន្ត ដើម្បីកសាងសមត្ថភាព ស្តីពីការតាមដាន វាយតម្លៃ និងដកពិសោធន៍ ក្របខណ្ឌ MEL នៅសណ្ឋាគារ សាន់អែនមូន។

- **លេខាធិការដ្ឋាន គ.ជ.ប.ជ**
  - លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ (១៣ច្បាប់) លិខិតចូល (២៣ច្បាប់)
  - លិខិតរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ(២៥ច្បាប់) លិខិតចូល (១៣ច្បាប់)
- **ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**
  - បានចូលរួមកិច្ចប្រជុំពិនិត្យវាយតម្លៃលទ្ធផលអនុវត្តលើកំណត់ហេតុ ស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំ២០២៥ និងត្រៀមចុះហត្ថលេខាលើកំណត់ហេតុ ស្តីពីកិច្ចសហប្រតិបត្តិការឆ្នាំ២០២៦ រវាងក្រសួងមហាផ្ទៃ នៃព្រះរាជាណាចក្រកម្ពុជា និងក្រសួងសន្តិសុខសាធារណៈឡាវ ក្រោមអធិបតីភាព ឯកឧត្តម អ៊ុ ម៉ារ៉ា រដ្ឋលេខាធិការក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ
  - បានចូលរួមជាមួយក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍ ចុះរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីកិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ នៅស្រុកថ្មពួក និងស្រុកមង្គលបុរី ខេត្តបន្ទាយមានជ័យ
- **ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**
  - បានអមដំណើរ លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ ចូលរួមសិក្ខាសាលា ស្តីពីបទដ្ឋានអន្តរជាតិ និងបច្ចុប្បន្នភាព នៃការងារប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទាន ភេរវកម្ម សម្រាប់អាជ្ញាធរអនុវត្តច្បាប់ ក្រោមអធិបតីភាព ឯកឧត្តម **ហេង បូមករា** ប្រធានអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅសាលប្រជុំ វិទ្យាស្ថានបច្ចេកទេស ធនាគារជាតិកម្ពុជា
  - បានចូលរួមសិក្ខាសាលាពិគ្រោះយោបល់បន្ត ដើម្បីកសាងសមត្ថភាព ស្តីពីការតាមដាន វាយតម្លៃ និងដកពិសោធន៍ក្របខណ្ឌ MEL នៅសណ្ឋាគារ សាន់ អេនមូន រាជធានីភ្នំពេញ។
- **ក្រុមជំនួយកិច្ចការយុត្តិធម៌**
  - បានចូលរួមកិច្ចប្រជុំរៀបចំរបាយការណ៍ នៃការអនុវត្ត គោលការណ៍ណែនាំរបស់ **ឯកឧត្តមអភិសន្តិបណ្ឌិត** ក្នុងពិធីបិទសន្និបាត បូកសរុបលទ្ធផលការងារ ប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ របស់ គ.ជ.ប.ជ ដឹកនាំដោយ ឯកឧត្តម ឧត្តមសេនីយ៍ទោ កែវ សុវណ្ណារ៉ា អគ្គលេខាធិការរង គ.ជ.ប.ជ នៅបន្ទប់ប្រជុំ គ.ជ.ប.ជ

- បានចូលរួមកិច្ចប្រជុំប្រធានអង្គភាពជំនាញប្រឆាំងការជួញដូរមនុស្ស លើកទី៤០ រៀបចំដោយ HSU-Philippines តាមប្រព័ន្ធវីដេអូ
- បានចូលរួមកិច្ចប្រជុំក្រុមការងារឧក្រិដ្ឋកម្មឆ្លងដែន ស្តីពីការជួញដូរមនុស្ស លើកទី២២ រៀបចំដោយ SOMTC-Philippines ក្នុងនាមជា Voluntary Lead Shepherd តាមប្រព័ន្ធវីដេអូ
- បានចូលរួមស្តាប់បទបង្ហាញ ស្តីពីព្រំដែនគោកនៃព្រះរាជាណាចក្រកម្ពុជា ជាមួយប្រទេសជិតខាង ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តម **ឡាំ ជា** រដ្ឋមន្ត្រីទទួលបន្ទុក រដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន នៅសាលប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ។

▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការជាតិនិងអន្តរជាតិ**

- បានចូលរួមជាអ្នកអង្កេតការណ៍ក្នុងកិច្ចប្រជុំប្រធានអង្គភាព ជំនាញប្រឆាំងការជួញដូរមនុស្ស (HSU) លើកទី៤០ រៀបចំដោយប្រទេសហ្វីលីពីន ក្នុងនាមជា the Chair of the ASEAN Ministerial Meeting on Transnational Crime (AMMTC) តាមប្រព័ន្ធវីដេអូ
- បានដឹកនាំក្រុមការងារ SOMTC-កម្ពុជា មានលោកឧត្តមសេនីយ៍ត្រី **អ៊ិន មាន** ប្រធានក្រុមជំនួយកិច្ចការ លោកស្រីវរសេនីយ៍ឯក **ថោង សុវត្ថិ** ប្រធានក្រុមជំនួយកិច្ចការយុត្តិធម៌ លោកឧត្តមសេនីយ៍ទោ **រស់ ណារិទ្ធ** អនុប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន ចូលរួមកិច្ចប្រជុំក្រុមការងារឧក្រិដ្ឋកម្មឆ្លងដែន ស្តីពីការជួញដូរមនុស្ស លើកទី២២ តាមប្រព័ន្ធវីដេអូ នៅបន្ទប់ប្រជុំ ទីស្តីការក្រសួងមហាផ្ទៃ រៀបចំឡើងដោយ ប្រទេសហ្វីលីពីន ដែលជាប្រធានអាស៊ានសមាសភាពចូលរួមកិច្ចប្រជុំមាន តំណាង SOMTC មកពីបណ្តាប្រទេសសមាជិកអាស៊ាន លេខាធិការអាស៊ាន តំណាង ASEAN-ACT សរុបប្រមាណ ៥០រូប។

▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**

- បានរៀបចំឯកសារត្រៀមចុះបណ្តុះបណ្តាល ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ នៅស្រុកថ្មពួក និងស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ
- បានចូលរួមវគ្គបណ្តុះបណ្តាល កិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំ ស្តីពីការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ និងមេរៀនសង្គ្រោះបឋមផ្លូវចិត្ត ដល់មន្ត្រី គ.ខ.ប.ជ ស្រុកថ្មពួក និងក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាព លោកជំទាវ អគ្គលេខាធិការ គ.ជ.ប.ជ នៅសាលប្រជុំនៃរដ្ឋបាលស្រុកថ្មពួក
- បានចូលរួមវគ្គបណ្តុះបណ្តាល កិច្ចការពារកុមារក្នុងបរិបទទេសន្តរប្រវេសន៍ និងផ្សព្វផ្សាយសេចក្តីណែនាំស្តីពី ការប្រមូលទិន្នន័យពលរដ្ឋធ្វើ ទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ និងមេរៀនសង្គ្រោះបឋមផ្លូវចិត្ត ដល់មន្ត្រី គ.ខ.ប.ជ ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ ក្រោមអធិបតីភាព លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំស្រុកមង្គលបូរី។

▪ **ក្រុមជំនួយកិច្ចការអនុវត្តច្បាប់**

- បានត្រួតពិនិត្យ និងបូកសរុបរបាយការណ៍ប្រចាំខែមេសា ឆ្នាំ២០២៦ របស់ក្រុមការងារអនុវត្តច្បាប់ ពីអគ្គស្នងការ ជូនទៅលេខាដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ១លើក
- បានត្រួតពិនិត្យ និងបូកសរុបរបាយការណ៍ផ្ទៃក្នុងរបស់ក្រុមការងារអនុវត្តច្បាប់ ប្រចាំខែមេសា ឆ្នាំ២០២៦ ជូនទៅលេខាដ្ឋាននៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ១លើក។

▪ **ខេត្តបន្ទាយមានជ័យ** បានចូលរួមសិក្ខាសាលាពិនិត្យសម្រេចលើខ្លឹមសារកែសម្រួលនៃគោលការណ៍ណែនាំ ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់ អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប។

▪ **ខេត្តប៉ៃលិន**

- បានចូលរួមកម្មវិធីផ្សព្វផ្សាយច្បាប់ ស្តីពីការប្រឆាំងការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា អនុក្រឹត្យលេខ ០៣អនក្រ.បក ស្តីពីការគ្រប់គ្រងសន្តិសុខ សុវត្ថិភាពតាមទីតាំងរស់នៅប្រមូលផ្តុំ បទបញ្ជា ០១បប ស្តីពីយុទ្ធនាការសម្អាតការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា នៅសាលប្រជុំសាលាខេត្ត
- បានចូលរួមកិច្ចប្រជុំប្រចាំខែ ដើម្បីតាមដានវឌ្ឍនភាពការងារបង្ក្រាបបទល្មើសឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា ក្រោមអធិបតីភាព ឯកឧត្តមសន្តិបណ្ឌិត **នេត សាវឿន** និងឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា** នៅសាលប្រជុំសាលាខេត្ត
- បានចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០២៤-២០២៥ និងលើកទិសដៅឆ្នាំ២០២៦-២០២៧ របស់គណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ក្រោមអធិបតីភាព លោកជំទាវបណ្ឌិត **ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** ប្រធានកិត្តិយសគណៈកម្មាធិការជាតិលើកកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ នៅសណ្ឋាគារសាន់ & ម៉ូនរីវើសាយ។

- លោកជំទាវ **បាន ស្រីមុំ** អភិបាល នៃគណៈអភិបាលខេត្ត បានអញ្ជើញចូលជាគណៈអធិបតី
  - ○ កិច្ចប្រជុំពិភាក្សាលើការរៀបចំផែនការចុះត្រួតពិនិត្យទីតាំងសង្ស័យ និងទីតាំងដែលត្រូវបានបង្ក្រាប និងបិទសៀលកន្លង មកពាក់ព័ន្ធនឹងករណីឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត
  - ○ កិច្ចប្រជុំផ្សព្វផ្សាយផែនការ ស្តីពីការបន្តនិរន្តរភាព យុទ្ធនាការបោសសម្អាតការឆបោកតាមប្រព័ន្ធបច្ចេកវិទ្យា( Online Scams) និងកិច្ចប្រជុំបូកសរុបលទ្ធផល នៃការចាត់តាំងការអនុវត្តគោលនយោបាយ ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ប្រចាំត្រីមាសទី១ ឆ្នាំ២០២៦ នៅសាលប្រជុំសាលាខេត្ត
  - ○ កិច្ចប្រជុំពិភាក្សា ស្តីពីការអនុវត្តច្បាប់ គោលនយោបាយ អនុសាសន៍របស់រាជរដ្ឋាភិបាល និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ ( ស៊ី-ដ/CEDAW ) នៅសាលប្រជុំសាលាខេត្ត។

- **ខេត្តកោះកុង** បានចូលរួមកិច្ចប្រជុំជំរុញការអនុវត្ត ការប្រមូលទិន្នន័យពលរដ្ឋធ្វើទេសន្តរប្រវេសន៍ និងកុមារក្នុងគ្រួសារទេសន្តរប្រវេសន៍ ចំនួន១លើក មានអ្នកចូលរួម៣០នាក់ ស្រី៨នាក់ នៅសាលប្រជុំសាលាក្រុងខេមរភូមិន្ទ។